# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភិយ-ប៊ុក
ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសត្ថា សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនបណ្ឌិត្យ | សេចក្ដីជូនដំណឹង រឿងទស្សនាវដ្ដី ១៩៥០ ... | ៨០១ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ព្រះរាជក្រឹត្យ ក្រមទសករិយា (តមក) ....... | ៨០៥ |
| លោក ភិយ-ប៊ុក ក្រមការ | ខភិទមហត្ថ:គន្ធី (តទៅ) .................. | ៨១៥ |
| — — | ប្រវត្តិសាស្ត្រនៃស៊ីវិល្បខ្មែរពួកណ៌ (តមក).... | ៨២០ |
| លោក ម៉ុញ-តាត្រី | ស័ព្ទបារាំងប្រែជាខ្មែរ (តមក) ............... | ៨២៥ |
| លោកសាង-សរ៉ិត លេខានុការ | រឿងព្រេងភូមា (តមក)...................... | ៨២៩ |
| អ្នកនាងញ៉ាវិបុលរាជសេនា នូ-កន | រឿងសាមកុក (តមក) ........................ | ៨៣៤ |
| — ទេពពិទូរ ឈឹម-ក្រសេម | ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) ....... | ៨៤១ |
| លោកផេង-ដឺរ | ប្រវត្តិរបស់អេសុប (តមក) .................... | ៨៤៦ |
| ផ្នែកសាសនា | | |
| លោក ភិយ-ប៊ុក ក្រមការ | គន្ធីអាស៊ីទូប (តមក) ......................... | ៨៥១ |
| យុគបណ្ណានុរក្ស រ៉ូ-ប៊ូ | កំឡុំងៈទំនាក្យញុះញង់........................ | ៨៥៦ |
| ព្រះគ្រូសាសនវង្ស គុយ-សូត្រ | សសបណ្ឌិតជាតក (រឿងសច្ចតាំសីល) ...... | ៨៦៣ |
| កំណត់ទិនប្រវត្តិការណ៍ | | |
| ពុទ្ធសាសនបណ្ឌិត្យ | ពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យ ជូនមករាជរដ្ឋាភិបាលខ្មែរ ............................. | ៨៧២ |


ឆ្នាំទី ២២ — លេខ ១១ វិច្ឆិកា ឆ្នាំ ១៩៥០ — តំឡៃជារៀល • ឆ្នាំ ១៤៥ រៀល ។

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

# TABLE DES MATIÈRES

## Partie littéraire :


| | | page |
|---|---|---|
| Institut Bouddhique | Annonce de la Revue Kambujà Suriyà 1951 | 801 |
| Luong Nibandhamatri Nhok-Thèm | Edit royal : Kramadasabhariyà (suite et fin) | 805 |
| M. Ray-Buc Kromokar | Paroles de Gandhi (suite) | 815 |
| —id— | Histoire de l'anciene civilisation Khmère (suite) | 820 |
| M. Menh-Nakry ancien député | Recueil des mots traduits par la Commission Culturelle (suite) | 825 |
| M. Sang-Savath, Secrétaire au Ministère des Finances | Contes birmans (suite) | 829 |
| Neak Oknha Vibularaja-séna Nou-Kân | Histoire de SAMKOK (suite) | 834 |
| Neak Oknha Debabidura Chhim-Krasem | Histoire du Royaume du Cambodge (suite) | 841 |
| M. Pheng Chhieu, professeur au Collège des Jeunes Filles | Biographie d'Esope (suite) | 846 |


## Partie religieuse:


| | | |
|---|---|---|
| M. Ray-Buc Kromokar | La lumière de l'Asie (suite) | 851 |
| Khun Pannanuraksa Bou-Po | Les effets de la calomnie | 856 |
| Preah Krou Sasanavongsa Kuy-Saut | Sasapanditajataka | 863 |


## Notes et Chroniques


| | | |
|---|---|---|
| Institut Bouddhique | Cérémonies de transfert de l'Institut Bouddhique au Gouvernement Royal. | 872 |


22e Année: No 11 — Mois de Novembre 1950 — Prix d'abonnement: 145$00 par an.

# សេចក្តីជូនដំណឹង

# អំពីពុទ្ធសាសនបណ្ឌិត្យ

## រឿងទស្សនាវដ្តី កម្ពុជសុរិយា

*សូមជំរាបជូនដំណឹងដល់បងប្អូនរួមជាតិទាំងឡាយ !*

ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៥០ នេះ អស់លោកអ្នកបានចុះឈ្មោះជាវ មានចំនួនច្រើនជាងឆ្នាំមុនៗ ។ ពុទ្ធសាសនបណ្ឌិត្យបានយល់ឃើញជាក់ស្តែងថា អស់លោក អ្នកស្រឡាញ់អក្សរសាស្ត្រ ទាំងឧបត្ថម្ភអក្សរសាស្ត្ររបស់ជាតិ ឲ្យលូតលាស់ចំរើនឡើងដោយពិតៗ ។ កិច្ចដែលបងប្អូនរួមជាតិស្ម័គ្រចុះឈ្មោះជាវច្រើនឡើងៗនេះ ឈ្មោះថាឲ្យកម្លាំងដល់ពួកអ្នកនិពន្ធក្នុងក្រុមយើង ឲ្យខំតែងខំរៀបរៀងនូវរឿងរ៉ាវថ្មីៗ ដែលមានសារប្រយោជន៍ច្រើន ទាំងខំរៀបចំរបៀបពាក្យពេចន៍ឲ្យរឹងរឹតតែពីរោះគាប់ចិត្តជាតិយោភាពឡើង ៗ យើងមានសង្ឃឹមថា អស់លោក-អ្នក មុខជានឹងចុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយា ក្នុងឆ្នាំ ១៩៥១ តទៅទៀត ហើយនឹងជួយផ្សាយដំណឹងអំពីប្រយោជន៍នៃទស្សនាវដ្តីយើង តៗទៅដល់បងប្អូនរួមជាតិដែលនៅជិតខាងជាពុំខានៗ

ឯរឿងរ៉ាវ ទាំងផ្នែកអក្សរសាស្ត្រទាំងផ្នែកសាសនា ដែលយើងយល់ឃើញថាមានប្រយោជន៍សំខាន់ដល់បងប្អូនរួមជាតិ ហើយបានត្រៀមទុកបំរុងនឹងបោះពុម្ពក្នុងឆ្នាំ ១៩៥១ ដូចមានរាយមាតិកា តទៅនេះ ៖

## ផ្នែកអក្សរសាស្ត្រ

១ – អក្សរសាស្ត្រខ្មែរ (គោលចារិកខាងផ្នែកអក្សរសាស្ត្រ ព្រម.
ទាំងពាក្យកាព្យឃ្លោងចាស់ៗ ឬទំនើបថ្មី) ។

២ – ព្រះរាជពង្សាវតារប្រទេសកម្ពុជា នៅមានបោះពុម្ពទៅទៀត ។

៣– ឯកសារ (រឿងរ៉ាវសំខាន់ៗ ដូចសិលាចារិកជាដើម) ។

៤ – រឿងសាមកុក នៅតែបោះពុម្ពទៅទៀត ត្រាតែចប់ ។

៥ – វប្បធម៌ (ពាក្យបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌) ។

៦ – សុភាសិតផ្សេងៗ របស់ជាតិយើងនិងនានាជាតិ ។

៧ – រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៨ – ទំនៀមទំលាប់ខ្មែរ របស់គណៈកម្មការទំនៀមទំលាប់ ។ល។

## ផ្នែកសាសនា:

១ – ដំណឹងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ។

២ – ធម្មទេសនា ដែលមានអត្ថរសប្លែកៗ ។

៣– សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ – និងជ្រើសប្រែរឿងក្នុងព្រះសូត្រ៖ ដែលជាផ្លូវប្រតិបត្តិ ។

## ប្រយោជន៍នៃទស្សនាវដ្ដីកម្ពុជសុរិយា

បងប្អូនរួមជាតិទាំងឡាយជ្រាបស្រាប់ហើយថា ទស្សនាវដ្ដីនឹងសារពត៌មាន ក្នុងប្រទេសយើង មានមិនលើសពី ២ - ៣ ឈ្មោះ

ប៉ុណ្ណោះ ។ ចំនួននេះបើយកទៅធៀបនឹងចំនួនទស្សនាវដ្ដី សារពត៌មាន ក្នុងប្រទេសគេជិតខាងប្រទេសយើង ឃើញថាខាងយើងតិចជាងគេឆ្ងាយណាស់ ស្ទើរតែកប់ថាមាននឹងគេពុំបាន ។ ខាងយើងដែលមានបញ្ញាបករណ៍តាំងនេះតិច មកពីយើងខ្មែរអ្នកស៊ំគ្រែអានមានចំនួនតិចនាក់; ខាងគេដែលមានបញ្ញាបករណ៍ច្រើន មកពីជាតិគេមានអ្នកចូលចិត្តអានច្រើន ។ បញ្ញាដែលជាផលកើតមកអំពីការអានច្រើននឹងការអានតិចតែងអនុវត្តទៅតាមគ្នា គឺបើក្នុងប្រទេសណា មានអ្នកអានច្រើននាក់ក្នុងប្រទេសនោះ អ្នកចេះដឹងក៏មានច្រើន; បើអ្នកអានមានតិច អ្នកចេះក៏មានតិច ។ ចំពោះរូបមនុស្សម្នាក់ៗ ក៏មានន័យដូចគ្នា គឺអ្នកណាអានច្រើន អ្នកនោះចេះដឹងច្រើន, អ្នកអានតិច ចេះដឹងតិច, អ្នកមិនអានសោះ ក៏មិនចេះសោះ សមដូចបុរាណសុភាសិតថា "បើអានពោះតិចច្រើន នឹងចំរើនសព្វថ្ងៃទៅ ដូចយំផប់ទឹកនៅ ផ្កាឈើក្រៅគគូមថាន" ។ ព្រោះជាទស្សនាវដ្ដី សារពត៌មាន ជាឃ្លាំងវិជ្ជា មានមុខការខាងបណ្ដុះដាំផ្សាំប្រាជ្ញានៃអ្នកអានឲ្យដើរទាន់សម័យ ។

វែនពិត ទស្សនាវដ្ដីយើងហើយនឹងអ្នកអាន ឈ្មោះថាឲ្យគម្រាំងផ្ដល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក ។ តាមន័យនេះ ឃើញថាបងប្អូនរួមជាតិដែលចេញសោហ៊ុយជាវទស្សនាវដ្ដីយើង បានផលជា ៣ ចំណែក គឺ:

១ – ជួយទស្សនាវដ្ដីយើងឲ្យមានអាយុស្ថិតនៅយូរអង្វែង

២ – កាលអស់លោក-អ្នកបានអានហើយ នឹងកើតមានប្រាជ្ញា ក្ដីស្មានក្នុងផ្លូវលោកផ្លូវធម៌

៣ – ផលជាកំពូល គឺអស់លោក-អ្នកនឹងមានកេរ្តិ៍ឈ្មោះថាជាអ្នកចាក់ទឹកស្រោចដីឲ្យអក្សរសាស្ត្រខ្មែរយើង ដុះលូតលាស់ចំរើនទាន់កាលសម័យ ឲ្យមានទឹកមុខស្មើនឹងអក្សរសាស្ត្រនានាជាតិ ៗ

ហេតុនេះ សូមអស់លោក-អ្នកដែលមានបំណងជាវទស្សនាវដ្ដីយើងប្រចាំឆ្នាំ ១៩៥១ សូមផ្ញើឈ្មោះបុះនាមទីលំនៅនឹងប្រាក់ចំនួន ១២៥ រៀល ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ក្នុងពេលឆាប់ៗ ៗ

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

Adress :

M. le S crétaire Général
de l'Institut Bouddhique
à Phnom-Penh

# ព្រះរាជក្រឹត្យ

# ក្រមទសភរិយា

ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះជ័យចេស្ដា (ចៅ ញាស្ហ) គ.ស. ១៦៩៣

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(ត-ចប់)

---

បើនាំម្រត់ទៅដល់ម្ដាយអាពុកបងប្អូនសាច់ញាតិអាប្រុសនោះហើយ បើម្ដាយអាពុកបងប្អូនសាច់ញាតិចងដៃកូនគេផ្សំនឹងកូនឯងនោះ . ត្រូវម្ដាយអាពុកបងប្អូនសាច់ញាតិ (ពិន័យ) អង្គពហុស័ក្ដិដីង ៣ តម្លឹង ១៧ ពិន័យអាប្រុសនាំរត់នោះដាច់ស៊ីវិលហោង ៗ ឲ្យខុនហូតយកខ្វាត់តម្លឹង ៣ ទីមួយខ្ទួន ខ្វាត់ព្រះឃុំងពុះគ្រឹងទីមួយខ្ទួនហោង ៗ បើម្រត់កូនគេខ្ញុំគេ ហើយបើកូនគេខ្ញុំគេហ្មាប់នៅព្រៃ ពុំបានដល់ស្រុកដល់ភូមិនោះឲ្យពិន័យតែអាប្រុសនោះដាច់ស៊ីវិលហោង ៗ ព្រះឃុំងពុះគ្រឹងហូតខ្វាត់ខ្ទុនភ្នាក់ងារតម្លឹង ៣ បើម្រត់ទៅដល់ស្លាប់នៅផ្ទះនៅភូមិនៅស្រុកគេនោះឲ្យពិន័យអាប្រុសដ៏នាំម្រត់តម្លឹង ៣០ ឯអ្នកបង្កាត់បន្សាំ តម្លឹង ១៨ តាមប្រការហោង ៗ

មាត្រា ១ សោត បើអ្នកណាចាប់ប្រពន្ធគេទាំងអំណាច (ដោយស្មាន) ថាជាកូនក្រមុំនោះ ត្រូវក្រយ៉ាពិន័យដីង ៣ តម្លឹង ១៧ ៗ បើចាប់កូនក្រមុំគេខ្ញុំគេនោះ យកស័ក្ដិមេបាអម្ចាស់មកពិន័យ បើស័ក្ដិ

ប្រុសនោះច្រើនឲ្យយកពិន័យក្នុងឯង ឲ្យហូតខ្វាតព្រះយ៉ាំងពុះត្រឹងដាក់ថ្វាយ ខ្វាត់ខុនក្លាក់ង៉ារតម្រឹង ៣ ។ បើម្រតកូនគេចៅគេខ្ញុំគេ បើម្តាយអាពុកអម្ចាស់ស្រីនោះពុំទឹងឡើយ ឲ្យប្រុសនោះទៅសំពះហើយយកខាន់ស្លាតិចក្តី ច្រើន (ក្តី) នោះសឹងយកខ្វាត់ព្រះយ៉ាំងវែងអំពីគង់ខាន់ស្លានោះឯង ។ បើម្តាយអាពុកម្ចាស់ ពុំលក់ពុំយកខាន់ស្លាអំពីប្រុសនោះឡើយ សឹងពប់អានទៅវិញទៅមកនោះ ឲ្យហូត (ខ្វាត់) ព្រះយ៉ាំងអំពីប្រុសតម្រឹង ៥ ឲ្យយកអំពីស្រី ៤ ខុនក្លាក់ង៉ារយកខ្វាត់អំពីប្រុសបាទ ១០ យកអំពីស្រីបាទ ៦ នូវៈដីងកោះស៊ឹង ១០ ទីមួយខ្ទួនហោង ។

មាត្រា ១ សោត បើសេចក្តីខ្ញុំគេម្រត់ បើអ្នកផងបង្អាត់បន្សំឲ្យក្រៀង ... ឲ្យបាយម្ហូបឲ្យអង្ករស្បៀង ស្លាម្លូទឹកផឹកក្តី ដណ្តើមទ្រព្យសម្បត្តិផងគ្នាក្តីទោះតួខ្ញុំក៏ដរ គោក្របីដំរីសេះក្តី បើចម្លងទឹងទូកទឹងក្បូន ទឹងក្របី មានគេដួលម្រត់អំពីម្ចាស់នោះក្តី ឲ្យខុនក្លាក់ង៉ារយកខ្វាត់ព្រះយ៉ាំងជាដង្វាយ តាមច្បាប់ខុនក្លាក់ង៉ារ តម្រឹង ៣ បាទ ៦ កំបាន តាមតិចច្រើន ។ បើកូនគេ ចៅគេ នូវកម្មោះនូវបំពេស នូវខ្ញុំគេ យកមកលក់នោះ ខុនក្លាក់ង៉ារហូតយកខ្វាត់តម្រឹង ៣ កំបាន បាទ ៦ កំបាន តាមតិចច្រើនហោង ។

មាត្រា ១ សោត បើអ្នកផងអ្នកជាខ្ញុំគេក្តី បើប្រកែកប្រវ៉ាយប្រឈ្លោះគ្នាដាល់តប់ខ្វាក្រចៅ ចាប់ក្បាលចាប់ដៃទាញសក់វាយទឹងដំបងវែក

ជាំជាម ឲ្យពិន័យតម្លឹង ១២ ហូតយកខ្វាត់ព្រះយ៉ាំងតម្លឹង ៦ ខុនក្មាក់ង៉ារហូតយកខ្វាត់តម្លឹង ៣ ជើងកោះស្ទឹង ១០ ទីមួយតួហោង ៗ បើក្រយាពិន័យតម្លឹង ៥ តម្លឹង ៤ តម្លឹង ៣ បាទ ៦ ខ្វាត់ជំនុំបានមកខុនក្មាក់ង៉ារ ១កញ្ញ៉ាស្មុភារទេពបតីនៅស្រុកក្រៅ បើក្រយាពិន័យតម្លឹង ១៥ ឲ្យបែងជាភាគ ៣ ភាគ ១ ព្រះយ៉ាំង ភាគ ២ ឲ្យខុនក្មាក់ង៉ារនូវចៅហ្វាយស្រុកហូតចែកតាមព្រះច្បាប់ ៗ បើពិន័យជើង ១ ហូតយក (ខ្វាត់) តម្លឹង ៨ ជាព្រះយ៉ាំង បើក្រយាពិន័យ ... (១) ៣០ ឲ្យខុនក្មាក់ង៉ារហូតតម្លឹង ៣ នូវសំណាលជើងតម្ងាច់ង៉សរូបហើយ ឲ្យតុះគ្រឹងជាព្រះយ៉ាំងថ្វាយ ៗ បើក្រយាពិន័យជើង ២ ជើង ៣ ជើង ៤ ជាងពីនោះក្តី សឹងហូតយកព្រះយ៉ាំងតុះគ្រឹងហោង ខ្វាត់ខុនក្មាក់ង៉ារតម្លឹង ៦ ហោង ៗ

មាត្រា ១ សោត បើអ្នកផងមានគេបាញ់តាក់កាប់ស្លាប់ក្តី របួសក្តី ពិការក្តី បើមានគេបាញ់សត្វស្រុកជើង ៤ ជើង ២ ក្តី សត្វត្រូវអន្ទាក់ក្តី ត្រូវអង្កប់ខ្វាក្តី បើតាក់ទឹងកាំបិតបោះគ្មានទឹងលំពែងក្តី មនុស្សក្តី សត្វជើង ៤ ក្តី ជើង ២ ក្តី បើមានគេវាយពោលបោះទឹងតំបងឫស្សី ឈើដីង ផ្តៅ ពកខ្វៃនោះ ឲ្យខុនក្មាក់ង៉ារហូតយកព្រះយ៉ាំងតុះគ្រឹងជាដង្វាយ ខ្វាត់ខុនក្មាក់ង៉ារ តម្លឹង ៣ ជើងកោះស្ទឹង ១០ ហោង ៗ

---

១ ត្រង់ណេះដូចជាបាត់ពាក្យ ១ ម៉ាត់ តម្លឹងឬជញ្ជីង តែតាមទំនងសេចក្តីនេះគួរបំពេញជាតម្លឹង ៣០?

មាត្រា ១ (សោត) អោះសេចក្ដីផ្ញើទ្រព្យរបស់ សេចក្ដីចាស់បងប្អូនអ្នកធំអ្នកតូចក្ដី សេចក្ដីអ្នកងងុសទឹងអ្នកធំទឹងអ្នកតូចទឹងជំទាវ នាងខុនណាង ទឹងឧកញ៉ា ព្រះ ហ្លួន ជី ទៅក្ដី សេចក្ដីសារពើរកយប់ថ្ងៃក្ដី អ្នកផងដើរខាងរបងគេបាត់របស់គេក្ដី សេចក្ដីស្រម៉ៃគ្នា ១ សេចក្ដីក្អាល់គ្នា ១ សេចក្ដីរើសទ្រព្យគេ ១ សេចក្ដីប្រឡងគ្នា ១ សេចក្ដីតិះដៀលគ្នា ១ សេចក្ដីថាគេជាប់ដំពូកជាអាយ៉តជាជងពារិ ១ សេចក្ដីទាំងនេះបើគេមកប្ដឹងចៅហ្វាយស្រុក ក្អាក់ងារស្រុក ទាំងអម្បាលណោះឲ្យចៅហ្វាយស្រុក នូវខុនក្អាក់ងារ នូវចៅពញាធម្មាពិក័ក្ដិជំនុំពិចារណា បើឯណាពុំព្រមចូលចិត្តនៅឡើយ ឲ្យចៅហ្វាយ (ស្រុក) ឲ្យដំណើរទៅក្ដីទាំងសងខាង នូវកំណត់ពាក្យមកដៃចៅធម្មាពិក័ក្ដិ នាំចូលទៅដល់ឲ្យឧកញ៉ាសុភាធិបតី សុភាមន្ត្រី ជំនុំពិចារណាតាមព្រះច្បាប់ ។

មាត្រា ១ សោត បើប្រុសលែងស្រី ឲ្យហូតខាត់តម្លឹង ៣ ជើងកោះស៊ឹង ១០ ទមួយខ្លួន ។ បើស្រីពុំលែងឡើយ ឲ្យចែករបស់សម្បជ្ជស្មើគ្នាហោង ។ លាងខ្មាសបារ ៦ ហោង ។

មាត្រា ១ (សោត) បើស្រីផង ទោះប្ដីស្លាប់មុនពុំទាន់លើកខ្មោចនៅឡើយ ល្អឹកតែនាងនោះទៅមានអន្ទករមានប្ដីពុំទាន់លើកខ្មោច ពុំទាន់បញ្ចុះធាតុនៅឡើយ នោះព្រះក្រឹត្យដីកាឲ្យពិន័យពេញបណ្ដាស័ក្ដិ ដូចប្ដីនៅរស់ធ្វើទោសតាមច្បាប់ ឲ្យខុនក្អាក់ងារហូតយកខ្វាត់តម្លឹង ៦ ហូតយក

(ខ្វាត់) ព្រះឃ្មាំងពុះគ្រឹង ឯទ្រព្យរបស់បិដាដង្វាយអស់ហោង នេះហៅកន្ទង់ខ្ទប់ ។ ១ សោត បើប្តីស្លាប់មុនពុំទាន់បញ្ចុះធាតុ នាំធាតុប្តីទៅផ្ញើនៅវត្តអ្នកព្រះសង្ឃក្តី នៅព្រៃក្តី ព្រះក្រឹត្យដីកាឲ្យពិន័យទាំងស្រីទាំងប្រុសពេញបណ្តាស័ក្តិ ដូចប្តីនៅរស់ ឲ្យប្រាណទឹកដោះតម្លឹង ៤ យកខ្វាត់ព្រះឃ្មាំងពុះគ្រឹង ខ្វាត់ខុនក្លាក់ងារតម្លឹង ៨ ឯទ្រព្យរបស់ជាដង្វាយអស់ហោងនេះហៅកន្ទង់ធាតុហោង ។ បើបញ្ចុះធាតុរួចហើយពុំចាំរក្សាទុកប្តីដល់កម្មង់ខែ ៨ ឡើយ លុះបើនាងនោះទៅមានអន្តករមានប្តីនោះឲ្យខុនក្លាក់ងារផ្សូសអស់ទ្រព្យរបស់ ខ្ញុំ គោ ក្របី ជាដង្វាយអស់ហោង ។

មាត្រា ១ (សោត) ទោះខ្ញុំគេនឹងខ្ញុំគេលួចប្រពន្ធគ្នា ឲ្យពិន័យបាទ ៦ នីមួយគូ ដើងកោះបាទ ៥ នីមួយគូហោង ។

មាត្រា ១ (សោត) ទោះខ្ញុំគេនឹងខ្ញុំគេយកគ្នាហើយលែង (គ្នា) វិញ ឲ្យខុនក្លាក់ងារហ្លួតខ្វាត់ស៊ឹង ៦ នីមួយគូ នូវដើងកោះបាទ ៥ នីមួយគូហោង ។

មាត្រា ១ (សោត) បើខ្ញុំគេនឹងអ្នកជាយកគ្នាហើយលែង (គ្នា) វិញ ឲ្យហ្លួតយកខ្វាត់នូវដើងកោះតាមដោយនូវខ្ញុំគេ នូវអ្នកជានោះឯងចៅហ្វាយស្រុក នឹងហ្លួតយកខ្វាត់ ១០ ស៊ឹងយកស៊ឹង ១ ហោង ។ ១ សោត សារពើសេចក្តីត្រូវមុខងារទុកញ៉ាសុភាធិបតី បើមានគេប្តឹង

ចៅហ្វាយស្រុកហូតខ្ញាត់ស្រុក ១០ យក ២ បើខុនក្អាក់ងារប្តឹងចៅហ្វាយស្រុក ហូតខ្ញាត់ ១០ យក ១ ហោង ។

មាត្រា ១ (សោត) ចៅហ្វាយនូវក្អាក់ងារប្តឹងប្រកោះមកហើយផ្សំផ្គុំប្រមូលទាំងស្រីទាំងប្រុសយកគ្នាវិញ ឲ្យខុនក្អាក់ងារយកតែខ្ញាត់ស៊ឹង ៦ នូវដើងកោះស៊ឹង ១០ ទីមួយតួហោង ។

មាត្រា ១ (សោត) បើប្តីប្រពន្ធបានក្រាបសំពះម្តាយអាពុក ហើយឥតទោស បើប្រលែងលែងគ្នា ឲ្យខុនក្អាក់ងារហូតខ្ញាត់តម្លឹង ៣ ទីមួយតួ នូវដើងកោះស៊ឹង ១០ ទីមួយតួហោង ។ បើប្រពន្ធបានផឹកកំណត់ហើយឥតទោសលែងគ្នា ឲ្យខុនក្អាក់ងារយកខ្ញាត់បាទ ៦ ទីមួយតួ ដើងកោះស៊ឹង ១០ ទីមួយតួហោង ។ បើប្រុសចង់លែង ស្រីពុំចង់លែង ឲ្យចែករបស់ស្មើគ្នា ហូតខ្ញាត់ ១០ យក ១ ។ បើស្រីចង់លែង ប្រុសពុំចង់លែង ឲ្យចែករបស់ (ទ្រព្យ) បានប្រុសភាគ ៣ ស្រីភាគ ១ ។ បើលែងស្មើគ្នា ឲ្យចែករបស់ជាភាគ ៣ ភាគ ២ បានប្រុស ភាគ ១ បានស្រីហោង ខុនក្អាក់ងារ ១០ ហូតយក ១ ហោង ។ បើប្រពន្ធជណ្តើងស៊ីស្លាសផ្កត់ហិបទៅហើយ ឥតទោសលែងគ្នា ឲ្យខុនក្អាក់ងារយកខ្ញាត់តម្លឹង ៣ ទីមួយតួ ដើងកោះស៊ឹង ១០ ទីមួយតួហោង ។ បើជាស្នូទអន្ទករទឹងគ្នា ហើយបានសំពះខ្មោចមេបាហើយ ឥតទោសលែងគ្នាវិញ ឲ្យខុនក្អាក់ងារហូតយកខ្ញាត់បាទ ៦ នូវដើងកោះស៊ឹង ១០ ទីមួយតួហោង ។

មាត្រា ១ ( សោត ) ពោះស្រីផងខុសកាចនឹងប្ដីគេហើយ ប្រពន្ធគេផឹងហើយគេដណ្ដឹង ( សួរ ) បើប្រាប់គេដោយពិត ថាខុសកាចនឹងប្ដីគេមែនហើយ ឲ្យស្រីនោះអណ្ដាប់ស្រាដបស្លាម្លូផ្ដិល ១ មកសំពះស្លាលាទោសនឹងប្រពន្ធគេសុះឥតទោសឡើយ ៗ ពោះខុសកាចនឹងប្ដី ( គេ ) ហើយអាចចងចិត្តឈ្លោះប្រកែកសាហាវនឹងប្រពន្ធគេ ថាខ្លួនឯងពុំខុសឡើយ លុះគេបើរកទៅឃើញយល់ថាខុសកាចមែននោះ ឲ្យដំស្រីនោះនឹងព្រ័ត្រកណ្ដាលផ្សារ ហើយឲ្យហែកសំពត់ផ្ទាប់ ៤ ឲ្យស្លៀក ហើយយកដាលក្អែកក្រួចច្រកក្បាលដល់ផ្លល់ស្មាមុខ ហើយដំឡើងដើងរនោល បើនឹងលោះខ្លួនជាប្រាក់តាមដោយព្រះច្បាប់ ជាចោរលួចប្ដីគេនោះហោង ៗ ឲ្យខ្លួនភ្នាក់ងារហូត ( ខ្វាត់ ) តម្លឹង ៦ ខ្វាត់ព្រះឃ្លាំងពុះគ្រឹងហោង ៗ ១ សោត បើប្រពន្ធស្លាប់មុនប្ដី ហើយប្ដីនោះពុំទាន់បានលើកខ្មោចបញ្ចុះធាតុប្រពន្ធនោះឡើយ បើទៅមានអន្លួករយកប្រពន្ធទៀតឥតសប្បុរសត់ធម៌ ឲ្យខ្លួនភ្នាក់ងារហូតខ្វាត់តម្លឹង ៣ នូវដើងកោះស៊ូង ១០ អំពីប្រុសនោះហោង ៗ

មាត្រា ១ ( សោត ) ពោះទៅលួចខ្ញុំគេ ( យក ) ទៅលក់ មានអ្នកដទៃគេទៅលោះបង្វែងទៅអំពីម្ចាស់ខ្ញុំនោះ បើដណ្ដឹងខ្ញុំនោះឃើញថាឥតស្គាល់ថាជាម្ចាស់វា ឲ្យប្ដឹងទៅក្រមព្រះសុភាឲ្យពិចារណា បានគូម្ចាស់ឯក្រោយ ៗ បើចាប់បានគូចោរដែលលួចទៅលក់នោះ ឲ្យពិន័យ ១ ជា ២

កុំប្រាណីឡើយ ឯខុនក្លាក់ឆ្ការហូតវាត់តម្លឹង ៣ ដើងកោះស៊ឹង ១០ វាត់ព្រះឃ្លាំងតម្លឹង ៦ បាទ ១ ហោង ។

មាត្រា ១ (សោត) ទោះទៅក្រមផងដំនុំសេចក្តីផងទាំងពួង ទោះទឹងប្រកាន់ចាប់ឆ្នោតក្តី ទោះឲ្យដណ្តឹងបន្ទាល់ក្តី ទោះឲ្យដណ្តឹងទឹងសត្យាប្រណិធានក្តី ទឹងឲ្យស្បថក្តី បើសរសេរទូតលើកទឹកក្លមអក្ខរសៀនទៀនប្រាក់មកហើយ ទៅម្ខាងប្រែពាក្យឆ្លើយថា ពុំចូលពុំទទួលឆ្នោតក្តី នោះយកអក្ខរសៀនទៀនទូវសត្យាប្រណិធានមកហើយ បើអ្នកក្តីម្ខាងៗប្រែឆ្លើយថា ពុំចូលពុំទទួលស្បថក្តី ទោះទឹងយកបន្ទាល់ឲ្យដណ្តឹងបន្ទាល់ក្តី ទឹងឲ្យស្បថប្រណិធានក្តី ទឹងឲ្យដណ្តឹងទេក្តី បើយកសត្យាប្រណិធានទូវអក្ខរសៀនទៀន ទូវអ្នកបន្ទាល់មកហើយ ឯអ្នកក្តីម្ខាងៗប្រែឆ្លើយថាពុំទទួល ពុំចូលចិត្ត ពុំទទួលដណ្តឹងវិញ នោះឲ្យទៅក្រមទុកសេចក្តីថាចាញ់ឲ្យពិន័យតាមច្បាប់ហោង ។

មាត្រា ១ (សោត) ទោះប្តីប្រពន្ធឈ្លោះគ្នា បើប្តីដំប្រពន្ធរត់ទៅចងកស្លាប់ បើរត់ទៅប្រាកដពិតឥតទោសប្រុសនោះឡើយ ឲ្យខុនក្លាក់ឆ្ការហូតយកវាត់ដើមឈើបាទ ៦ ដើងកោះស៊ឹង ១០ អំពីប្តីបងប្អូននៅរស់ផ្ទះជាមួយហោង ។ បើប្រុសទៅចងកស្លាប់ ឲ្យហូតវាត់តម្លឹង ៣ ទូវដើងកោះស៊ឹង ១០ អំពីប្រពន្ធបងប្អូនដែលរស់នៅ បើឥតទោស ។

មាត្រា ១ (សោត) ទោះប្រពន្ធដប្តី ឈ្មោះនឹងប្តីវិញ ព្រះក្រឹត្យដីកាឲ្យដប្រពន្ធនោះ ១០០រំពាត់ បើលោះរំពាត់ ១ ជាប្រាក់បាទ ១ ឲ្យគ្រប់រំពាត់ទាំងអស់ ឲ្យខុនភ្នាក់ងារ (ហូត) យកខ្នាត់គម្ទឹង ៣ ទូរ ដើរកោះស៊ឹង ១០ ខ្នាត់ព្រះយ៉ាំងតុះគ្រឹងហោង ៗ

មាត្រា ១ (សោត) បើសេចក្តីអាជ្ញានាំព្រះបន្ទូលទូវសំបុត្រចេញចូលទៅ ទោះអាជ្ញាខុសនឹងអ្នកស្រុក (ៗ) ខុសនឹងអាជ្ញាក្តី ដណ្តើមខ្ញុំទូវរបស់សម្បត្តផងគ្នា សេចក្តីចែកផ្នែកមេផ្នែកបាក្តី ទោះសេចក្តីប៉ាគ្នាជាខ្ញុំជាជំពូក ជាបំពេស ជាអាយ័តក្តី សេចក្តីទារយកសារពើគុណអំពីគ្នាក្តី បើរើសទ្រព្យរបស់គេក្តី ដំពាក់អ៊ីៗ គ្នាក្តី សេចក្តីសគ្រោះលោះញាតិក្តី សេចក្តីផាច់អាយាត់បំពេសក្តី សេចក្តីយកខ្លួនទៅបញ្ចាំទ្រព្យគេ យកកំឡាំងទ្រព្យគេទាំងអម្បាលណោះ ឲ្យខុនភ្នាក់ងារយកខ្នាត់ក្រយាពិន័យតិចច្រើននោះហោង ៗ បើបានជាខ្នាត់ព្រះយ៉ាំងឲ្យវែងជាភាគ ៣ ភាគ ១ បានចៅហ្វាយស្រុក ភាគ ២ បានកញ្ញាសុភាទេពបតី ៗ សេចក្តីរំលងសារពើទ្រព្យគេ ១ សេចក្តីញាតិអាស្រ័យរកគ្នាឡើងចុងដូងចុងត្នោតឡើងសារពើឈើផង ទោះធ្លាក់ស្លាប់ក្តី ទោះរបួសពិការក្តី ១ ទោះសេចក្តីត្រូវខ្មោចមេបានឹងឲ្យប្រុសសំពះខ្មោច ១ សេចក្តីចូលទិស ១ ចូលត្រណមហើយដម្កាត់ស្លាប់ ១ សោតឲ្យចែករបស់សម្បត្តជាភាគ ៤ ភាគ ១ បានស្រី ភាគ ៣ បានប្រុស ៗ

បើស្រីចង់លែងប្រុសៗ ពុំចង់លែងស្រីឡើយ បើប្រុសចង់លែងស្រីៗ ពុំចង់លែងប្រុសឡើយ ឲ្យចែករបស់សម្បត្តិជា ២ ភាគ ភាគ ១ បានប្រុស ភាគ ១ បានស្រី ។ ឯច្បាប់ឲ្យព្រះសុភាពិចារណាគេទោសទាំងស្រីទាំងប្រុស បើស្រីទោសធ្ងន់ហើយលែងប្រុស ឲ្យជាត់តែទ្រព្យដើមចេញឲ្យ (ស្រី) ឯទ្រព្យសម្បត្តិបានប្រុសអស់ហោង បើទោសសមគួរស្រីលែងពុំបានឡើយ បើឥតទោសប្រុសលែងបានហោង ។

មាត្រា ១ (សោត) ច្បាប់ព្រះរាជក្រឹត្យ (នេះ) ត្រូវមុខងារទុកញ៉ាសុភាធិបតីទាំងអម្បាលណោះ បើពុំបានប្រាប់ខុនក្លាក់ងារសុភាធិបតីឲ្យបានដឹងនោះ ទុកជាមេបាម្តាយអាពុកបាំងបំបាំងមុខងារ ព្រះបាទអ្នកជាអម្ចាស់ត្រាស់ពហូស័ក្តិ ឲ្យពិន័យដីង ៣ ដម្លឹង ១៧ ហោង ។

នេះច្បាប់ទសគរិយាសួរេចចប់ម្ល៉េះឯងហោង ។

(នេះច្បាប់ទសករិយា អ្នកទុកញ៉ាពិភ័ក្តិសេនី ចារចប់ នៅថ្ងៃ ៦ កើតខែពិសាខ ឆ្នាំថោះឧក្សត្រ ឯកស័ក ២០) ។

សុភាសិត

ឃ្លាន ឆ្ងាញ់. ស្រឡាញ់ ល្អ.
សមិនដែលខ្មៅ សៅរ៍មិនដែលស្រុក,
កុកតែងភ្លេចជង់ មនុស្សល្ងង់បិតមួមៗ
ស្ងួរមាត់ជួ កុំឲ្យជួបិត្ត ។

រ. ប.

ឧត្តមមហាត្មៈគន្ធី

# លោក វ៉ាយ-ប៊ុក ក្រុមការនៅពុទ្ធសាសនបណ្ឌិត្យ.

*ដកស្រង់ពីសារពត៌មាន ហ្សឺន អាំង (Jeune Inde)*

(តមក)

---

*៤៩ – ចំពោះជនជាបច្ចាមិត្រ នឹងកល្យាណមិត្រ យើងមិនត្រូវយល់ថា មានសភាពផ្សេងគ្នាទេ ។*

*... ការពិសោធន៍ធ្វើឲ្យយើងឃើញថា បើអំណោយដ៏ប្រសើរជាឧបសគ្គចំពោះការចំរើននៃសីលធម៌វិញទេ ត្រូវតែយើងបំផ្លាញនូវអំណោយនោះឲ្យវិនាសសាបសូន្យទៅ កុំឲ្យមានចិត្តរួញរា កុំឲ្យគិតពីសំណាងដែលត្រូវសងអ្វីឡើយ ។*

*... ការស្រឡាញ់សំពត់បរទេស ជាហេតុឲ្យបរជាតិមានឥស្សរភាពលើប្រទេសរបស់ខ្លួន ទាំងជាហេតុនាំមកនូវសេចក្ដីទុក្ខព្រួយលំបាក ហើយនាំឲ្យមានសេចក្ដីខ្មាសអៀនក្នុងវង្សត្រកូលជាច្រើន ដែលជាផលដ៏លាមកបំផុត ។*

*... មុននឹងការពារនូវគុណធម៌អ្នកដទៃ ត្រូវយើងការពារខ្លួនយើងកុំឲ្យបាបធម៌លុកលុយចូលមកក្នុងសន្ដានយើង ។*

សេចក្ដីថ្លែងពីហាយឥភាព

ថ្ងៃទី ១ វិគុណា ១៩២១

៩០ – ផ្លូវនេះ (ប្រទេសឥណ្ឌា) មានផ្លូវពីរៈ ១– បញ្ចូលគោលការណ៍ដែលគេនិយមប្រើនៅមជ្ឈិមប្រទេស គឺពលភាពពីលើច្បាប់ ។ ២– រក្សាទុកនូវគោលការណ៍បូព៌ាប្រទេស ។ ផ្លូវទាំង ២ នេះជាធម៌ពិតអាចនាំទៅកាន់ជោគជ័យ ដែលមិនចេះអាប់ឱន ហើយដែលអ្នកមានកំឡាំងនឹងអ្នកទុព្វលភាពមានសិទ្ធិស្មើគ្នាចំពោះសេចក្តីយុត្តិធម៌ ។

...អ្នកណាដែលរស់នៅដោយប្រើអាវុធ អ្នកនោះមុខជាស្លាប់នឹងអាវុធ; គេឃើញមានអ្នកចេះហែលទឹកយ៉ាងចំណានលង់ទឹកស្លាប់ក៏មាន ។

...កិច្ចការដែលធ្វើឲ្យជឿនទៅមុខ មិនមែនសុទ្ធតែវឌ្ឍនធម៌ទេ ។

... គ្មានផ្លូវអ្វីវិសេសជាងផ្លូវនៃធម៌ពិត ។.

**នវជីវន** (Nava Zivan)

**ថ្ងៃ ៨ ខែមិថុនា ១៩២១**

៩១ – អ្នកណាដែលមិនចេះពោលនូវពាក្យពិត អ្នកនោះប្រៀបដូចជាប្រាក់ក្លែងក្លាយដែលគ្មានដំឡៃ ។

...ពួកបណ្ឌិតខាងវិទ្យាសាស្ត្រពោលថាៈ បើគ្មានពលភាពអាចភ្ជាប់បរមាណូធាតុ ដែលមាននៅក្នុងលោកឲ្យជាប់រួមគ្នាបានទេ លោកសន្និវាសនេះមិនអាចស្ថិតស្ថេរនៅបាន នឹងវិនាសបែកធ្លាក់ព្រាត់ព្រាយ ហើយយើងនឹងមិនអាចមានជីវិតរស់នៅឡើយ, ប្រៀបដូចជាកំឡាំងភ្ជាប់ធាតុដែលមាននៅក្នុងធម្មជាតិមានសភាពជាអវិញ្ញាណកៈ, កំឡាំងនោះក៏ស្ថិតនៅក្នុងសត្វ ដែលមានជីវិតក្នុងពិភពលោកដែរ; កំឡាំងដែលចង

ជាតុឲ្យភ្ជាប់មូលគ្នា ដែលប្រមូលសត្វមានជីវិតឲ្យប៉ះរួមគ្នានេះ គឺសេចក្ដីស្នេហា ។

... សេចក្ដីស្នេហានៅត្រង់ណា ជីវភាពក៏នៅត្រង់នោះ ... សេចក្ដីស្អប់នាំសត្វទៅកាន់សេចក្ដីវិនាស ។

ខ្ញុំសូមឲ្យលោកអ្នកជឿជាក់ថា: យើងមិនអាចទៅកាន់សេចក្ដីចំរើនបានទេ បើយើងមិនបានទុកការប្រព្រឹត្តនូវធម៌ពិតថាជាសភាពមានដំឡៃបំផុត ។

ប៉េរីត្យ នឹងជិឡៃ
ថ្ងៃ ៦ វិច្ឆិកា ១៨២១

៩២ - ករីបណ្ឌិតបានពោលដោយសង្ខេបថា: កុំឲ្យជឿនូវពាក្យណាដែលមានន័យចំពាស់ប្ដូរយនឹងវិចារណញាណប្ដូរយនឹងចិត្តយើង ។

... ខ្ញុំអាចយល់ពិតប្រាកដបានថា: ការចូលមកសូមទទួលសារភាពដោយសេចក្ដីល្ងង់នៃអ្នកដែលជាទីស្រឡាញ់ រមែងធ្វើឲ្យវិនាសជាងការទទួលសារភាពចំពោះមុខតែនៃចណ្ឌាល (Tyrans) ។ អ្នកដែលនៅក្រោមបង្អាប់ចិត្តពាលមានសេចក្ដីសង្ឃឹមខ្លះ, ចំណែកអ្នកដែលនៅក្រោមឱវាទនៃសេចក្ដីស្នេហា គ្មានសេចក្ដីសង្ឃឹមសោះឡើយ ។ សេចក្ដីស្នេហាមានប្រយោជន៍ត្រង់ការឲ្យកំឡាំង ដល់ជនណាដែលទុព្វលភាព ។ សេចក្ដីស្នេហាអាចក្លាយទៅជាសភាពលាមក ដោយការបង្ខំជនណាដែលមិនព្រមជឿឲ្យប្រតិបត្តិតាមចិត្តខ្លួន ។

...ព្រះដែលបង្កើតមនុស្សជាតិមក ព្រះអង្គចង់ឲ្យមនុស្សនោះរស់នៅដោយសារបំពេញកិច្ចការទាំងពួង ហើយព្រះអង្គមានព្រះបន្ទូលថា "ជនណាដែលបរិភោគអាហារមិនបានធ្វើការអ្វីសោះ ជននោះគេទុកជាពួកចោរ" ។

... ខ្ញុំចូលចិត្តត្រង់ការចំរើន ខ្ញុំចូលចិត្តធ្វើការអ្វីៗសម្រេចចំពោះខ្លួនឯង, ខ្ញុំពេញចិត្តខាងសេរីភាព ។ តែការទាំងនេះ ខ្ញុំចង់ឲ្យបានប្រយោជន៍ដល់អាត្មន, ខ្ញុំមានសេចក្ដីសង្ស័យថា: សម័យ "ដែកថែប" វិសេសជាងសម័យ "សិលា" ។ ចំណែកសេចក្ដីយល់ឃើញនៃខ្ញុំបែបនេះមិនជាអ្វីទេ គឺយើងត្រូវព្យាយាមប្រើប្រាជ្ញាយ៉ាងមុះមុត នឹងអាយតនៈឯទៀតគ្រប់យ៉ាង ដើម្បីនឹងធ្វើវឌ្ឍន៍នៃអាត្មន ។ ខ្ញុំគិតយល់ឃើញថាមិនជាការពិបាកទេត្រង់ការស្មានថា មនុស្សម្នាក់បានពាក់គ្រឿងបែបទាហានតាមសម័យ អាចរកឃើញនូវវត្ថុដែលសំខាន់ មានសភាពស្អិតស្ថេរយូរអង្វែងចំពោះការរួមនៃមនុស្សជាតិ ។ ខ្ញុំគិតថា ជាការងាយបំផុតត្រង់ការប្រែថា អ្នកណាដែលក្រីក្រមានតែដុំគ្រួសមួយនឹងដែកគោលមួយ ដើម្បីនឹងបំភ្លឺផ្លូវដែលខ្លួនត្រូវទៅ, អាចសំដែងធម៌, សរសើរនូវគុណនៃព្រហ្មវិហារផ្សាយទៅកាន់ភពដែលរងនូវសេចក្ដីទុក្ខដោយថ្លែងសារលិខិត ញុំាងសត្វលោកឲ្យបានប្រកបដោយសន្តិសុខនឹងមានមនោមយិទ្ធិដ៏ក្លៀវក្លាបានក្នុងលោកសន្និវាសនេះ ។

... សេដ្ឋកិច្ចខាងនយោបាយឯណាដែលធ្វើឲ្យអន្តរាយនូវសេចក្តីសុខនៃបុគ្គលនីមួយៗ ឬប្រជាជាតិនីមួយៗ សេដ្ឋកិច្ចនយោបាយនោះជាការទំនាស់នឹងសីលធម៌ ហើយគេទុកជាបទឧក្រិដ្ឋពេញទី ។ សេដ្ឋកិច្ចខាងនយោបាយឯណា ដែលធ្វើឲ្យប្រទេសមួយទៅលួចប្លន់ប្រទេសមួយ សេដ្ឋកិច្ចនយោបាយនោះជាការទំនាស់នឹងសីលធម៌ ។ គេទុកជាអំពើបទឧក្រិដ្ឋ ចំពោះអ្នកណាដែលទិញវត្ថុដែលបានមកពីការបែងចែកមិនគ្រប់គ្រាន់ ហើយយកវត្ថុទាំងនោះទៅធ្វើជាប្រយោជន៍ផ្ទាល់ខ្លួន ។ ខ្ញុំទុកជាអំពើបទឧក្រិដ្ឋ បើខ្ញុំបរិភោគស្រូវសាលីអាមេរិក ហើយខ្ញុំធ្វើអ្នកជិតខាងដែលមានស្រូវសាលី មិនឲ្យមានអ្នកណាមកទិញយកទៅបរិភោគបាន ខ្ញុំទុកខ្លួនខ្ញុំជាអ្នកបង្កហេតុឲ្យអ្នកទាំងនោះអនិច្ចកម្មដោយទុក្ខភ័យ ។

... មុននឹងគិតបែងចែក ត្រូវស្វែងរកឲ្យបានមកសិន ។ កិច្ចការដែលមិនព្រមនៅក្រោមបង្គាប់បញ្ជានៃពលករ មិនមែនជាការជំទាស់នឹងជនជាតិអង់គ្លេស ឬនឹងលទ្ធិបច្ចិមប្រទេសទេ; ការនេះ គឺគ្រាន់តែបំពេញកិច្ចដើម្បីនឹងតស៊ូនូវរបៀប ដែលពួកជនជាតិអង់គ្លេសបានស្ថាបនានៅទីនេះ ។

... កណ្តុរដែលឆ្មាខាំស៊ីដោយហេតុថា កណ្តុរនោះជាសត្វខ្សោយការពារខ្លួនឯងមិនបាន; មិនមែនជាការគាប់ប្រសើរគ្រង់ធ្វើពលិកម្មដោយគេបង្ខំនោះទេ ។

ការរងចាំពិនិត្យម៉ាំខួន

ថ្ងៃ ១៣ តុលា ១៩២១ (មាតេ)

# ប្រវត្តិសាស្ត្រនៃស៊ីវិល្បៃខ្មែរបុរាណ

លោក សឺដេស៍-ស៊ីដែស តែង

## លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

បើព្រះមហាក្សត្រនឹងពួកមន្ត្រីជាន់ខ្ពស់ មានគេកត់ត្រាទុកដោយជាក់លាក់ក្នុងសិលាចារិកខ្លះ ឯពួកប្រជាករដែលគេទុកជាហីនភាព គេមិនសូវមានពណ៌នាក្នុងសិលាចារិកនោះទេ ។ ដូចជានៅប្រទេសឥណ្ឌាពួកប្រជាករមានចែកជាក្រុមតាមវិជ្ជាជីវៈ ដែលមួយក្រុមៗ បានអប់រំ ។ ការដែលស្រាវជ្រាវនូវសិលាចារិកអាចប្រមូលរឿងរ៉ាវគ្រប់យ៉ាងដែលមានសារៈសំខាន់ ជាហេតុឲ្យអ្នកប្រាជ្ញជាន់ក្រោយពិនិត្យនូវសេចក្តីប្រែប្រួលដែលកើតឡើង អំពីទំនៀមទម្លាប់ហិណ្ឌូចំពោះវណ្ណៈដែលចូលមកស្ថិតនៅអាណាចក្រខ្មែរបាន ។ ព្រះមហាក្សត្រទ្រង់ជាអ្នករក្សាទុកនូវប្រពៃណីផ្សេងៗ ហើយនឹងរបៀបវណ្ណៈ មានព្រះរាជសិទ្ធិបង្កើតជាថ្មីនូវប្រពៃណីទំនៀមទម្លាប់ប្ដូររបៀប ។ មានសិលាចារិកមួយបានពណ៌នាអំពីរឿងប្រែប្រួលច្បាប់ទំនៀមទម្លាប់ជាថ្មី គឺៈ ក្រុមសង្ឃការីនៃព្រះមហាក្សត្របានជ្រើសរើសរកបុរសប្រហែល ២០ នាក់សម្រាប់តវង្សត្រកូលចំពោះនវវណ្ណៈ ហើយនាំយកទៅថ្វាយព្រះមហាក្សត្រចំពោះព្រះអគ្គី, ព្រាហ្មណ៍និងនាយកនៃពលរដ្ឋ; ព្រះករុណាទ្រង់ឲ្យពរ

សព្វសាធុការមានចាត់រៀបចំផ្កាជាដង្វាយ ហើយព្រះអង្គបានថ្វាយការទូវ ឯកសិទ្ធិដែលព្រះអង្គព្រះរាជទានចំពោះនរវណ្ណៈ សិលាចារឹកនៃឯកសិទ្ធិ ហើយនឹងសេចក្ដីរាយការនៃពិធីនេះ បានចារឹកទុកនូវផែនមាសដែលបាន រក្សាទុកនៅមន្ទីរឯកសារនឹងផែនប្រាក់ដែលបានរក្សាទុកនៅព្រះបរមរាជ-វាំងនឹងផែនថ្មស្ថិតនៅគ្រប់ភូមិ នៃបុរសដែលបានជ្រើសរើសយកមកជា មេបង្កាត់ពូជគ្រប់វណ្ណៈ ។

ដោយហេតុថាយើងត្រូវការពណ៌នាអំពីភូមិ, យើងត្រូវឲ្យយល់ថា ភូមិទាំងនោះមានចាស់ព្រឹទ្ធាចារ្យនឹងពួកមន្ត្រីឃុំជាអ្នកត្រួតត្រា ដែលមាន អធិប្បាយនៅតាមសិលាចារឹក ដើម្បីនឹងបញ្ជាក់នូវបុព្វហេតុនៃកម្មសិទ្ធិដី ភូមិព្រមទាំងបោះគោលព្រំប្រទល់ ។ ចំពោះជីវភាពនៃពួកក្សេត្រករនឹង ពួកពលរដ្ឋក្នុងភូមិ, គេបានដឹងរឿងរ៉ាវបន្តិចបន្តួចមានពោលថាពួកទាំង នេះច្រើនមានពួកក្រុមជាន់ខ្ពស់គេចាត់ឲ្យទៅធ្វើជាទាសករនៅក្នុងបូជនិ-យដ្ឋាន, ព្រះវិហារឬអាស្រម ដោយហេតុថាពួកឧត្តមក្រុមនេះច្រើនមាន បសាទសទ្ធាចំពោះសាសនាផ្សេងៗ ។ សិលាចារឹកនោះបានសំដែងអំពី បញ្ជីដែលចុះនាមពួកទាសករនេះ ដែលមិនបានដឹងថានាមឈ្មោះខ្លួនមាន សភាពមិនពីរោះពិសារ (ឆ្កែ, ឆ្មា, ស្អប់, សំអុយ) ហើយជាពាក្យមើល ងាយដោយត្រង់នោះអាចគស្ដូបាននូវសេចក្ដីប្រមាថនៃកាល ហើយរក្សា ទុកនូវកេរ្តិ៍តំណែលមកឲ្យជនជាតិខាងក្រោយ ។

តាមវត្ថុធាតុផ្សេងៗ នៃស៊ីវិល្បៃខ្មែរបុរាណ បើតាមធម្មជាតិនៃបុព្វហេតុអក្សរចារិកនៅដែនខ្មែរ សាសនាក្នុងពេលនោះយើងអាចដឹងបានដោយជាក់លាក់ គឺមកពីសាសនាដែលនាំឲ្យកើតទូវក្បាច់រចនាផ្សេងៗនៃខ្មែរសម័យបុរាណ វៀវតែស្ពានដែលមានរបាំងរចនាជារូបនាគដែលមានសភាពជាទីគោរព, ប្រាសាទខ្មែរទាំងអស់សុទ្ធតែជាបូជនិយដ្ឋាន ហើយកំពែងនគរក៏មានសភាពដូចគ្នា ព្រោះកំពែងនោះគឺជាកំពែងខាងក្រៅនៃព្រះវិហារដែលស្ថិតនៅកណ្ដាលនគរ ។

តាំងពីបុព្វហេតុនៃព្រះរាជអាណាចក្រខ្មែរ មកដល់សតវត្សទី ៦ ហើយមកដល់សម័យអង្គរ, សាសនាឥណ្ឌូជាសាសនាគោរពព្រះសិវៈ ឬព្រះវិស្ណុ ហើយរួបរួមទាំងពីរព្រះអង្គទៅជាសាសនាហរិហរៈ ជាព្រះដែលមានព្រះរូបប្រតិស្ឋានដោយរូបព្រះសិវៈនឹងព្រះវិស្ណុដែលជាមូលលទ្ធិនៃសាសនាហិណ្ឌូ, ចំណែកខាងព្រះពុទ្ធសាសនាមានពួកនាំយកជាច្រើន ហើយព្រះមហាក្សត្រអង្គខ្លះបានចាត់ការឲ្យគោរពជាផ្លូវការ ។ ក្នុងសតវត្ស ១២ មានការកែទម្រង់មួយចំពោះសាសនានេះខាងប្រទេសភូមា, លាវ, សៀម, កម្ពុជា, ដល់មកចុងសតវត្សទី ៩ ពួកជនគុបុគ្គលនៃប្រាសាទអង្គរមានសទ្ធាយ៉ាងមោះមុតចំពោះសាសនានេះបានកសាងវត្តជាច្រើននៅខាងត្បូងស្រះធំ ដែលព្រះអង្គទ្រង់បានចាត់ឲ្យជីក ។ យើងបានស្គាល់វត្តនោះបីតាមសិលាចារិក : វត្តមួយសម្រាប់ពួកឧបាសកដែល

គោរពព្រះសិវៈ, វត្តមួយទៀតសម្រាប់ពួកនាយកដែលវន្ទាព្រះវិស្ណុ, វត្តទី ៣ សម្រាប់ពួកពុទ្ធបរិសទ្យ ។ សាសនាគារៈ ជាផ្ទះការនៃព្រះបរមរាជវាំងនឹងរដ្ឋាភិបាល គឺការគោរពនូវព្រះស្ដេចគឺរូបស្ដេចប្រតិស្ឋានទុកឲ្យប្រជារាស្ត្រគោរព ដូចជាព្រះដែលជាបដិមាករប្រស់ទ្ធីតំណាងព្រះមហាក្សត្រដំកល់ទុកកណ្ដាលព្រះវិហារដែលស្ថិតនៅចំកណ្ដាលព្រះរាជធានី ។ ប៉ុន្តែមិនមែនតែព្រះមហាក្សត្រមួយទេ ដែលគេទុកជាព្រះនៅលើផែនដី ដែលជាមូលដ្ឋានអាចឲ្យកើតសាសនាគារៈមួយផ្ទាល់ព្រះអង្គ ។ ក្នុងសម័យអង្គរមានសិលាចារឹកជាច្រើន អាចបញ្ជាក់ឲ្យឃើញនូវសាសនាគារៈមួយចំពោះរូបចំឡាក់ដែលមានគេគន់គ័ណ្ឌជាអសេខបុគ្គល ក្នុងព្រហ្មញ្ញសាសនានឹងពុទ្ធសាសនា តែរូបទាំងនោះប្រតិស្ឋានឡើងដំនួសសម្មតិនាមបុគ្គលដែលមរណភាពទៅហើយ ឬបុគ្គលដែលមានជីវិតរស់នៅ ។ មានរូបចំឡាក់ជាច្រើនជាតំណាងព្រះខីណាស្រព, អសេខបុគ្គលដែលប្រទេសកម្ពុជាសម័យបុរាណបានរក្សាទុក នូវបដិមារូបតំណាងសេខបុគ្គលខាងសាសនាហិណ្ឌូ ។ បដិមារូបទាំងនោះច្រើនមានរូបភាពជាព្រះមហាក្សត្រិយ៍ ព្រះអង្គម្ចាស់ ឬជាមន្ត្រីធំៗ ប្រតិស្ឋានរូបជាព្រះ គឺមានព្រលឹងចាកចេញលោកនេះ ទៅកាន់លោកខាងមុខក្លាយទៅជាព្រះ ។ ព្រះបដិមារូបនោះ មានចារឹកតាមឈ្មោះដោយបញ្ចូលនាម

បុគ្គលដែលអធិប្បកម្មទីឯនាមព្រះបដិមាករ បង្ហាញឲ្យឃើញថាសាសនាគារវៈនោះជាការគោរពចំពោះបុគ្គល ។

នេះជារឿងក៏សំខាន់ដ៏សាសនាគារវៈចំពោះបុគ្គលដែលជាបុព្វហេតុនៃការកសាងប្រាសាទខ្មែរទាំងនោះ មិនមែនដូចជាព្រះវិហារយើង ដែលកើតឡើងមកពីគារវៈនៃពលរដ្ឋ. គឺជាប្រាសាទដែលព្រះមហាក្សត្រព្រះរាជបុត្របុរដ្ឋមន្ត្រីកសាងឡើង ដើម្បីដំកល់ព្រះអដ្ឋិធាតុ ហើយគេទុកជាព្រះស្តូបឬចេតិយ ដែលជាហេតុនៃសាសនាគារវៈចំពោះជីដូនជីតា, ចេតិយទាំងប៉ុន្មានគេស្អាងតាំងពីបុគ្គលទាំងនោះមានជីវិតរស់នៅ ។

គឺមកពីរបៀបពិធីក្នុងការសម្ពោធឲ្យប្រាសាទទាំងនោះបានជាមានសិលាចារិកដែលជាប្រភពសំខាន់ ដែលយើងបានស្រាវជ្រាវទុកជាវិជ្ជានៃមហាស៊ីវិល្ស៊ែខ្មែរបុរាណ ។ សិលាចារិកនោះមានបង្ហាញនូវគំនិតផ្សេងៗ ដោយជាក់លាក់អំពីការចាត់អង្គការនៃព្រះវិហារ ឬសមាសភាពនៃបុគ្គលិកក្នុងព្រះវិហារនោះ មាននាយក, សាស្ត្រាចារ្យ, បព្វជិត, អ្នករាំទិក (ភ្លេងមហោស្រពតូរ្យតន្ត្រី), អ្នកច្រៀង, នាងនាដកា (របាំ), នាយទ្វារបាល, នាយពិសេស (ចំអិនម្ហូបអាហារ), នាយគ្រងបុប្ផានិងពួកបរិវារ, ទាសកម្មករប្រុសស្រីជាច្រើនដែលគេជួលទៅធ្វើបរស្រែ ដែលជាកេរ្តិ៍មរតករបស់វត្តនោះ ។

( មានត )

# សព្ទបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

## លោក មិុញ-តាំគ្រី រូបរួម

(តមក)

---

Monnaie = រូបិយវត្ថុ

Territoire = អាណាខេត្ត, ដែនដី

Le mécanisme des changes = របៀបប្តូរ

Barrière = របាំង

Faciliter = សម្រួល

Recherche = ការស្វែងរក

Organisme sanitaire = អង្គការសុខភាព

28–11–49

Traitement = ប្រព្រឹត្តិកម្ម

Domaine = ផ្នែកការ

Bien = ទ្រព្យសម្បត្តិ

Point de vue = ន័យ

29 11–49

Fiscalité = សារពើពន្ធ

Régime juridique = នីតិវិធី

| | |
|---|---|
| Législation = | និតិកម្ម |
| Particulier = | ដោយឡែក |
| Spécial = | ពិសេស |
| Instance civile = | បទរដ្ឋប្បវេណី |
| — commerciale = | ពាណិជ្ជកម្ម |
| — pénale = | អាជ្ញា |
| Privilège juridictionnel = | ឯកសិទ្ធិខាងតុលាការ |
| | 30–11–49 |
| Membre sociétaire = | សង្គមិកសមាជិក |
| — souscripteur = | សមាទិកសមាជិក |
| Ordre = | សេចក្តីរៀបរយ |
| Garnison = | យោធភូមិ |
| | 6–12–49 |
| Directive = | សេចក្តីដឹកនាំ |
| Conduite générale = | លំនាំការទូទៅ |
| Lettre de créance = | សារតាំង |
| | 9–12–49 |
| Habilité = | និតិសម្បទា |
| Convention = | អនុសញ្ញា |
| Obligation civile = | កិច្ចបេជ្ជា |
| | 20–12–49 |

Réciprocité = បដិការ

Organisme constitutionnel = អង្គការរដ្ឋធម្មនុញ

Droit = នីតិសាស្ត្រ

Statut personnel = លក្ខន្តិកៈផ្ទាល់ខ្លួន

Droit privé = ច្បាប់ឯកជន

Etat = សភាវៈ

Capacité = សមត្ថភាព

Le contentieux administratif = ក្រមវិវាទខាងរដ្ឋបាល

23—12—49

Qualification = គុណវុឌ្ឍិ

Qualité = គុណសម្បត្តិ

អង្គារ ១០ — ១ — ១៩៥០

Facultatif = តាមបុាន, មិនបានបង្ខំ

សុក្រ ១៣ — ១ — ១៩៥០

Patrimoine = បេតិកភ័ណ្ឌ

អង្គារ ៣១ កក្កដា ១៩៥០

Commandement en chef = អគ្គបញ្ជាការ

Officier des cadres Cambodgiens = នាយទាហានជាតិខ្មែរក្នុងក្របខ័ណ្ឌ

Sans aucune discrimination = ដោយឥតរើសមុខឡើយ

Commande = បញ្ជាទិញ

សុក្រ ៣ កុម្ភ ១៩៥០.

La Légionétrangère = កងសាបរទេស

Servitude = បរិបារភាព

Recrutement = ការជ្រើសរើស

អង្គារ ៧ កុម្ភ ១៩៥០.

Permanence = និច្ចការ, និច្ចកាល, អចិន្ត្រៃយភាព

Permanent = ជានិច្ច, អចិន្ត្រៃយ

សុក្រ ១០ កុម្ភ ១៩៥០

Croix-Rouge = កាកបាទក្រហម

Parité = យុគភាព, ការធៀបតម្លៃ(ប្រាក់)

អង្គារ ១៤ កុម្ភ ១៩៥០

Hamonie = សុខដុម

Droit de préemtion = សិទ្ធិបុព្វក្រយ

Portée = ដរភាព

សុក្រ ១៧ កុម្ភ ១៩៥០

(មានត)

រឿងព្រេងភូមា

លោក សាង-សាភីត លេខានុការ ក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

---

## ៨ – សេចក្ដីស្នេហាពិត

*" គ្មានពលិកម្មឯណាមួយអាចផ្ទុកទម្ងន់ទៅលើទឹកចិត្តដែលស្រឡាញ់ពិតបានឡើយ " ។*

គ្មានពលិកម្មឯណាមួយអាចផ្ទុកទម្ងន់ទៅលើទឹកចិត្តដែលស្រឡាញ់ពិតបានឡើយ ។ ជនណាមានទុក្ខធំបំផុត ជនៈនោះធ្វើពលិកម្មដោយសប្បាយបំផុតដែរ ។ នេះជាសញ្ញារបស់សេចក្ដីស្នេហាពិត ។

នៅក្នុងពេលដដែល ដែលមានរឿងរបស់យើងក្រោយបង្អស់នេះ គឺក្នុងសាសនាព្រះពុទ្ធកូណាគង្គ (Gaunagong) ដែលទ្រង់គង់ព្រះជន្មបានបីម៉ឺនព្រះវស្សា ។ នៅក្នុងស្រុកកម្បូត្សា (Kambautsa) មានសេដ្ឋី ៤ នាក់ ចងស្ពានមេត្រីនឹងគ្នាយ៉ាងមុតមាំ ។ បណ្ដាសេដ្ឋីទាំង ៤ នោះ សេដ្ឋីបីនាក់មានកូនប្រុសមួយៗម្នាក់ ។ ឯសេដ្ឋីទី ៤ មានកូនស្រីមួយ ដែលមានរូបឆោមយ៉ាងល្អឆើតឆាយ ។

កូនកំលោះនៃសេដ្ឋីទាំងបីនាក់ មានចិត្តស្រឡាញ់នាងនោះជាពន់ពេក ហើយបានចូលខ្លួនទៅដណ្ដឹងដល់ឪពុកម្ដាយរបស់នាងតែ

រៀងខ្លួន ៗ គង់ពេលនោះឪពុកម្តាយរបស់នាង មុននឹងសម្រេចរឿងនេះ, ដោយការបង្ខំចិត្តបុរសទាំងបី ទើបសួរទៅអ្នកទាំងនោះថា: បើសិនណា មានកម្មអាក្រក់មកផ្តាច់ជីវិតកូនស្រីរបស់ខ្ញុំ មុនពេលដែលមិនទាន់ដល់អាយុរៀបការ តើអ្នកណាគិតយ៉ាងណាខ្លះ? បើអ្នកណាគិតត្រូវគួរសម ខ្ញុំនឹងឲ្យកូនស្រីរបស់ខ្ញុំទៅអ្នកនោះ! ។

ចំនួនច្រើនថ្ងៃក្រោយមក បុរសទាំង៣បានផ្ញើសំបុត្រឆ្លើយមកឪពុកម្តាយរបស់នាងរៀងខ្លួន ៗ បុរសទី ១ និយាយថា: បើសិនណាកម្មអាក្រក់នាងស្លាប់មុនអាយុ ១៥ ឆ្នាំ ខ្លួនខ្ញុំនឹងជានាយកខ្មោចនាងទៅបូជានៅកន្លែងមួយដែលធ្វើនឹងដៃឯង រួចខ្ញុំខ្នះខ្នែងធ្វើបុណ្យឲ្យនាងតាមព្រះពុទ្ធប្រវេណីអំពីបុរាណ ៗ បុរសទី ២ សន្យាថា: បើសិនណានាងមានវាសនាអាក្រក់អស់អាយុមុនពេលរៀបមង្គលការ ខ្ញុំនឹងប្រមូលធាតុនាងដែលធ្វើឈាបនកិច្ចរួចហើយ យកទៅបញ្ចុះកន្លែងមួយយ៉ាងល្អអស្ចារ្យ ដែលមានដើមអម្ពិលទឹកមានម្លប់ត្រឈឹងត្រឈៃ ៗ ចំណែកខាងបុរសទី ៣ និយាយយ៉ាងខ្លីថា: បើសិនណាគ្រោះកាចនោះមានមកដល់រូបនាង ខ្ញុំនឹងយកធាតុនាងទៅបញ្ចុះកន្លែងមួយ រួចដេកនៅទីនោះជាអចិន្ត្រៃយ៍ ទាំងយប់ទាំងថ្ងៃទាល់តែស្លាប់បង់ជីវិតទៅ ៗ ឪពុកម្តាយរបស់នាងអានចប់ហើយងក់ក្បាល ដោយពេញចិត្តនឹងពាក្យចំឡើយនៃសេដ្ឋបុត្រទាំងបីនាក់នេះ ៗ

ឱគួរអនិច្ចាហ្ន៎! គង់ពេលនោះ វាសនាបណ្តាលឲ្យនាងស្លាប់មុនអាយុ

១៩ ឆ្នាំមែន ។ ឪពុកម្ដាយរបស់នាងកើតទុក្ខជាអនេក បានអង្វរឲ្យបុរសទាំងបីបំពេញកិច្ចសន្យារបស់ខ្លួនកុងគ្រានោះ ។ បុរសទាំងបីក៏បានធ្វើដោយឥតរួញរាទៀយ ។ បុរសទី ១ យករូបនាងទៅបូជា ។ បុរសទី ២ យកឆ្អឹងទឹងផេះទៅដាក់កុងផ្នូរមួយយ៉ាងល្អ ។ រួចបុរសទី ៣ ទៅដេកនៅទីផ្នូរនោះទាំងយប់ទាំងថ្ងៃ ។

ដល់យូរថ្ងៃក្រោយមក មានអ្នកសច្ចំម្នាក់ដែលដើរក្នុងព្រៃហិមពាន្ត បានឃើញបុរសអង្គុយទុនខ្លួន មានទឹកមុខស្រងូតស្រងាត់សំឡឹងមើលផ្នូរនាង ។ លោកឈប់ហើយសួរទៅបុរសនោះថា : តើអ្នកអង្គុយធ្វើអ្វីនៅទីនេះ ។ បុរសប្រថុយស្លាប់និយាយមួយៗប្រាប់លោកវិញសព្វស្រេចក្ដីអំពីសេចក្ដីមរណៈរបស់នាងទឹងអំពីពាក្យសន្យារបស់ខ្លួនដែលថាសុខចិត្តដេកនៅទីផ្នូររបស់នាងដល់ស្លាប់ជីវិត ។ អ្នកសច្ចំមានចិត្តអាណិតបុរសនោះជាពន់ប្រមាណដោយឃើញថាបុរសនេះស្រឡាញ់នាងពិត ។ រួចលោកសួរថា: តើចៅឯងសប្បាយចិត្តឬទេ បើសិនណានាងនេះរស់ឡើងវិញ? ។

បុរសនោះយំមានទឹកភ្នែកហូរស្រស្រាក់ឆ្លើយវិញថា: ចិត្តខ្ញុំប្រាថ្នាធំបំផុតត្រង់ឲ្យនាងរស់ឡើងវិញ ។ កុងពេលនោះ អ្នកសច្ចំក៏សូត្រអាគមគាថាឡើង ផ្នូរមួយស្របក់ស្រាប់តែនាងលេចចេញពីក្នុងដីឡើងល្អឯករកអ្វីប្រៀបពុំបាន ។ នាងឥតនិយាយអ្វី ស្រាប់តែដើរតម្រង់ទៅផ្ទះរបស់ឪពុកម្ដាយនាងវិញ ។ ឯឪពុកម្ដាយរបស់នាងដូចអ្នកផងប្រាជ្ញ ស្រាប់ហើយ គាត់មានចិត្តសប្បាយឥតឧបមា ។

លុះកាលណាបុរសទី ១ ដឹងរឿងដ៏ចំឡែកនេះក៏ទៅរកឪពុកម្ដាយរបស់នាងដែលកំពុងសប្បាយ ហើយនិយាយថា: ខ្ញុំបានយករូបនាងទៅដុតខ្លួនខ្ញុំ រួចខ្ញុំបានធ្វើបុណ្យបញ្ជូនឲ្យនាងតាមប្រពៃណី ; ឥឡូវនាងរស់ឡើងវិញហើយ តើនាងត្រូវបានមកខ្ញុំមែនឬទេ? ។

បុរសទី ២ ថា: ខ្ញុំបានយកធាតុនាងទៅបញ្ចុះក្នុងផ្នូរមួយយ៉ាងល្អ ឯរូបនាងដែលរស់ឡើងវិញនេះត្រូវបានមកខ្ញុំ ។

បុរសទី ៣ និយាយថា: ខ្ញុំបានដេកនៅលើផ្នូររបស់នាង, ខ្ញុំបានអង្វរអ្នកសច្ចំឲ្យប្រោសនាង តើខ្ញុំគ្មានអំណាចអ្វីលើនាងទេឬ? បើខ្ញុំមានគុណលើរូបនាងយ៉ាងដូច្នេះ; ប៉ុន្តែយើងកុំឈ្លោះគ្នា ព្រោះយើងដឹងចិត្តគ្នាស្រាប់ហើយ យើងមិនអាចសម្រេចការណ៍នេះបានដោយខ្លួនយើងទេ, យើងត្រូវនាំគ្នាទៅរកព្រះនាងខត្តិយានី ធូដាម៉្នាសារី (Thoudamna sari) ព្រះនាងជាស្រីមានប្រាជ្ញា ហើយសុចរិតត្រឹមត្រូវផង, បើអ្នកទាំងអស់គ្នាសុខចិត្ត យើងត្រូវទៅប្ដឹងឲ្យព្រះនាងសម្រេចរឿងនេះឲ្យ ។

ឯឪពុកម្ដាយរបស់នាងនិងរូបនាងក៏ព្រមព្រៀងឲ្យបុរសទាំងបីទៅប្ដឹងព្រះនាងខត្តិយានី ដោយឥតបង្អង់ឡើយ ។

ព្រះនាងលុះកាលណាបានស្ដាប់សព្វសេចក្ដីហើយ បានវិនិច្ឆ័យសេចក្ដីដូចតទៅនេះ :

" ខ្ញុំបានស្ដាប់យល់អស់ហើយ ; បុរសទី ១ លុះកាលណានាងស្លាប់បានយករូបនាងទៅដុត, ដល់អណ្ដាតភ្លើងឆាបឆេះឡើង បុរសរូបនេះ

ទៅបាត់ទៅដោយឥតគិតអ្វីទៀតសោះ ។ បុរសទី ២ បានរើសជាគូនាង ទៅដាក់កន្លែងផ្នូរមួយយ៉ាងស្អុកស្អម. ដល់កាលណាដាក់រួចហើយ បុរសរូបនេះទៅរកស៊ីបាត់ទៅ ។ ឯបុរសទី ៣ មិនបានទៅណាមកណា ដូចគេឯទៀតទេ, បុរសរូបនេះលែងរវល់នឹងការងាររកស៊ីលោកយើងនេះ ហើយទៅដេកនៅលើផ្នូររបស់នាង ចាំងយប់ចាំងថ្ងៃ មិនគិតខ្វាចដល់ទំនៀមទម្លាប់ស្រុកយើងដែលថ្លែងថា បើមនុស្សណាទៅយាមផ្នូរខ្មោច ក្រមញាតិមនុស្សនោះត្រូវហូតងារ ហើយបំបែកចេញពីសញ្ជាតិចំនួន ៧ តំណ ។ អាស្រ័យហេតុនេះ សេចក្ដីស្នេហារបស់បុរសនេះមានធំជាងអ្នកទាំងពីរនាក់, គឺរូបបុរសនេះហើយដែលត្រូវបាននាង ដើម្បីតបស្នងដល់សេចក្ដីមេត្រីរបស់គេ; មួយទៀតដោយសារតែដេកនៅនឹងផ្នូរនេះហើយបានជានាងរស់មានជីវិតឡើងវិញយ៉ាងប្លែកអស្ចារ្យនេះ, បុរសនេះនឹងមិនបោះបង់នាងក្នុងពេលដែលនាងមានវិបត្តិ; មានតែរូបបុរសមួយនេះទេ ដែលអាចរក្សានាងដោយសួស្ដីជាបតទៅ " ។

នេះហើយសេចក្ដីអាក្រក់របស់ព្រះនាងខត្តិយានី ។ បន្ទាប់ពីនោះមក គេរៀបពិធីមង្គលការអាពាហ៍ពិពាហ៍ឡើងដោយអធិកធិក ។

សុភាពបុរសទាំងឡាយ ! អ្នកត្រូវធ្វើតាមសទ្ធិចរិយានេះ ។ អ្នកគោរពដឹងថាការសម្រោះមានថ្នាក់ ៗ មួយទៀត ត្រូវដឹងផងនូវសេចក្ដីស្នេហាដោយទំហំពលិកម្មដែលជាប់នៅលើរបស់ដែលគេស្រឡាញ់ ។

រឿងសាមកុក

ភាគទី ៧

# អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

នាងតៀវសៀនបានឮដូច្នោះ ក៏រឹតតែធ្វើកលមាយាឲ្យតាំងតុះជាប់ចិត្តឡើងទៀត ។ អងអ៊ុនឃើញដូច្នោះក្រាកលុតជង្គង់គំនាប់តាំងតុះហើយថា សព្វថ្ងៃនេះខ្ញុំបាទមានសេចក្ដីសុខព្រោះបុណ្យគុណអំណាចលោក ខ្ញុំបាទនឹងរកអ្វីតបព្រះគុណគ្មាន មានតែនាងតៀវសៀនជាកូនចិញ្ចឹមនេះ ខ្ញុំបាទក៏ស្រឡាញ់ទុកដូចជាកូនបង្កើត ខ្ញុំបាទសូមលើកជូនជាស្រេចដល់លោក ។ តាំងតុះបានឮដូច្នោះ ក៏មានសេចក្ដីត្រេកអរជាពន្លឹក ទើបតបថា ដែលលោកមានដួងចិត្តគិតលើកនាងតៀវសៀនឲ្យដល់ខ្ញុំនោះ ខ្ញុំនឹងតបស្នងសងគុណលោកតទៅ ។ អងអ៊ុនទើបឲ្យគាត់ចែងទ្រព្យរបស់ជាគ្រឿងសំពត់អាវសារស្បៃដ៏មានដំឡៃ រៀបដំណើរឲ្យនាងតៀវសៀន

ជាច្រើន ហើយឲ្យឡើងជិះរថ ចាត់ឲ្យមនុស្សម្នាហែហមទៅដល់លំនៅឋានតាំងគុះ ក្នុងស្រុកក្រុងនៅវេលាយប់នោះ ។

ឯតាំងគុះនោះកាលឃើញអង់អ៊ុនចាត់ប្រើមនុស្សម្នា ឲ្យនាំខ្លួននាងតៀវសៀនទៅឲ្យដូច្នោះ ក៏លាអង់អ៊ុនចេញទៅ ។ ក្នុងពេលនោះអង់អ៊ុនក៏ជូនដំណើរតាំងគុះទៅដល់ផ្ទះហើយលាត្រឡប់វិលមកវិញ, ចេញមកដល់ពាក់កណ្ដាលផ្លូវទទួលជួបនឹងលីប៉ោជិះសេះកាន់ខ្លួនមកតាមុខ ។ លីប៉ោឈប់ចាប់ជាយអាវអង់អ៊ុនហើយសួរថា នាងតៀវសៀននោះខ្លួនលើកឲ្យជាភរិយាយើងហើយ ហេតុម្ដេចក៏បញ្ជូននាងទៅឲ្យមហាឧបរាជវិញ ដែលខ្លួនធ្វើដូច្នេះនឹងបញ្ឆោតយើងលេងទេឬ? ។

អង់អ៊ុនតបថា ទីនេះជាកណ្ដាលផ្លូវ ខ្ញុំនឹងជំរាបអ្នកឲ្យអស់សេចក្ដីមិនបាន សុំអញ្ជើញអ្នកទៅផ្ទះខ្ញុំមួយរំពេចសិន ខ្ញុំនឹងជំរាបរឿងនេះឲ្យបានជ្រាប ។ លីប៉ោតាមទៅដល់ផ្ទះអង់អ៊ុន ៗ នាំលីប៉ោឡើងទៅលើល្វែងផ្ទះហើយនិយាយថា អ្នកកុំអាលខឹងសំបានឹងខ្ញុំ ៗ នឹងជំរាបឲ្យជ្រាបៈ កាលពីព្រឹកមិញ ខ្ញុំបានចូលទៅគាល់ព្រះចៅហៀនតេ មហាឧបរាជបាននិយាយនឹងខ្ញុំថា មានកិច្ចនឹងត្រូវការចង់ទៅរកខ្ញុំឯផ្ទះក្នុងពេលថ្ងៃត្រង់, ខ្ញុំបានរៀបក្រយាហារទុកជូនពិសា, លុះមហាឧបរាជទៅពិសាហើយលោកសួរខ្ញុំថា មានគេទៅជំរាបថាខ្ញុំលើកនាងតៀវសៀនជាកូនឲ្យធ្វើជាភរិយាអ្នក, ខ្ញុំបានទទួលថាមែន, មហាឧបរាជថាចង់សុំមើលខ្លួន, ខ្ញុំឲ្យ

នាងតៀវសៀនចេញមកគំនាប់, មហាឧបកជបានឃើញរូបនាងហើយថា ដែលខ្ញុំលើកកូនឲ្យអ្នកជាបុត្រធម៌មហាឧបកជនោះ មហាឧបកជមានសេចក្តីពេញចិត្តណាស់ និយាយនឹងខ្ញុំថា ថ្ងៃនេះឫក្សពេលល្អហើយនឹងសុំយកខ្លួននាងតៀវសៀនទៅរៀបការនឹងអ្នកជាកូន ឲ្យនៅរួមសុខទុក្ខនឹងគ្នាតាមប្រវេណី; ដែលមហាឧបកជថាដូច្នេះ អ្នកប្រគិតមើលទៅចុះ ខ្ញុំជាអ្នកតូចនឹងអាចដែរទទឹងបានឬ? ខ្ញុំទើបបញ្ជូនកូនឲ្យទៅ ។

លីប៉ូបានស្តាប់ទើបឆ្លើយថា "ខ្ញុំបាទដែលក្រោធនឹងលោកនោះខុសហួសទៅហើយ សូមឲ្យលោកអភ័យទោសចុះ" ថាហើយលាទៅវិញ កងវេលាយប់នោះស្រួតទៅដល់ផ្ទះតាំងតុះ ហើយចាំស្តាប់ដំណឹង ជាតាំងតុះនឹងគិតរៀបការឲ្យមែនឬប្រការម្តេចបានជាមិនមានព្អើសោះ ។ លុះព្រឹកឡើងលីប៉ូឡើងចូលទៅកងវែងផ្ទះសួរស្រីបំរើថា មហាឧប-កជនៅឯណា ? ។ ពួកស្រីប្រាប់ថា លោកមិនដឹងទេឬ យប់មិញមហា-ឧបកជបានស្រីរូបល្អម្នាក់មក ឥឡូវកំពុងសម្រាន្តនៅឯកង ។ លីប៉ូបានស្តាប់ដូច្នោះខឹងក្តៅឈឺលកងចិត្ត ទើបដើរចូលទៅអែបស្តាប់ក្បែរជញ្ជាំង ។ ឯនាងតៀវសៀនក្រោកពីដំណេកមុនតាំងតុះ ចេញទៅលប់មុខ ក្រឡេកឃើញស្រមោលចូលទៅតាមបង្អួច ក៏អើតចេញទៅមើលឃើញលីប៉ូ ។ នាងតៀវសៀនធ្វើជាយំ ហើយយកសំពត់ជូតទឹកភ្នែក ។ លីប៉ូឃើញដូច្នោះ រិតតែមានចិត្តខឹងក្តៅនឹងតាំងតុះខ្លាំងណាស់ ទើបដើរត្រឡប់ចេញទៅវាងក្រៅ ។

កាលតាំងតុះភ្ញាក់ឡើងចេញទៅខាងមុខ, លីប៉ោក៏ឡើងទៅវិញ តាំងតុះសួរថា ថ្ងៃនេះមានការរកជការអ្វីខ្លះ? លីប៉ោឆ្លើយដោយសំឡេងទ្រគោះថា គ្មានការអ្វីទេ ៗ តាំងតុះក៏នៅស្ងៀមហើយបរិភោគអាហារ ៗ លីប៉ោចូលទៅឈរពីខាងក្រោយតាំងតុះតាមទម្លាប់ ៗ ឯនាងតៀវសៀនផាត់សក់ចេញហើយងាកមុខមើលទៅឃើញលីប៉ោ ធ្វើជាបោលភ្នែកក្រឡេកទៅប្រទះនឹងភ្នែកលីប៉ោៗ រិតតែមានសេចក្ដីអាណិតស្រឡាញ់ជាច្រើន ៗ ឯតាំងតុះជួនជាបោលភ្នែកក្រឡេកទៅឃើញជាក់ជាលីប៉ោសំឡឹងមើលនាងតៀវសៀនច្រើនដងដូច្នោះ ក៏មានចិត្តប្រច័ណ្ឌ ទើបនិយាយនឹងលីប៉ោថា ថ្ងៃនេះគ្មានការអ្វីទេ បើត្រូវការទៅផ្ទះ ក៏ទៅចុះ ៗ លីប៉ោត្រូវដូច្នោះក្រឡេកមើលទៅមុខនាងតៀវសៀនម្ដងទៀត. ហើយដកដង្ហើមធំរួចចុះទៅ ៗ

កាលតាំងតុះបាននាងតៀវសៀនមកទុកនោះ ក៏មានសេចក្ដីស្រឡាញ់ពេញចិត្តវង្វេងជាប់ក្នុងកាមដោយមាតុគ្រាម ក៏ភ្លេចចេញមកនិយាយការជាង ១ ខែប្វាយ ៗ ពេលណាដែលតាំងតុះមានជម្ងឺឈឺ, នាងតៀវសៀនតែងមានសេចក្ដីឧស្សាហ៍ គក់ប្រចាំបំរើម្រាសតាំងតុះមិនឲ្យមានសេចក្ដីទាស់ក្នុងគំនិតឡើយ ៗ តាំងតុះរិតតែមានសេចក្ដីស្រឡាញ់ពេញចិត្តនឹងនាងតៀវសៀនទ្វេគុណឡើងទៀត ៗ

មានថ្ងៃ ១ លីប៉ោចូលទៅសួរដល់ខាងក្នុងផ្ទះ តាំងតុះកំពុងតែដេកលក់ នាងតៀវសៀនឃើញលីប៉ោចូលមកងាកខ្លួនចេញទៅខាងក្រៅមុន

ធ្វើកលមាយា យកដៃបង្អួលទៅត្រង់តាំងគុះ ហើយបង្អួលទៅដើមទ្រូងរបស់ខ្លួន ហើយយំអណ្ដឺតអណ្ដកក្នុងវីនោះ ៗ លីប៉ោដឹងក្នុងកិរិយាដែលនាងតៀវសៀនធ្វើនេះ រិតតែមានសេចក្ដីស្នេហាស្រឡាញ់ឡើងថែមជាស្អប់ខ្នាញ់នឹងតាំងគុះទៅវិញ ៗ

ចំណែកតាំងគុះភ្ញាក់ឡើងឃើញលីប៉ោចូលទៅ ក៏លបលួចគយគន់មើលរកកប្បកិរិយា ឃើញលីប៉ោលួចសំឡឹងទៅនាងតៀវសៀនខាងក្រោយមុងដូច្នោះ ក៏ខឹងណាស់ស្រែកគំហកថា "នែអាលីប៉ោអាអប្រិយ! អញខំប្រឹងយកឯងមកចិញ្ចឹមរក្សាទុកដូចជាកូនបង្កើត ។ បង់កំឡាំងសោះ, អាឯងចិត្តធំហានលួចស្រឡាញ់ប្រពន្ធអញ" ថាហើយបង្គាប់ស្រីបំរើឲ្យបណ្ដេញលីប៉ោចុះពីលើផ្ទះហើយប្រាប់ថា តាំងពីថ្ងៃនេះទៅ កុំឲ្យវាចូលមកផ្ទះអញទៀត ៗ ពេលនោះលីប៉ោមានសេចក្ដីអៀនខ្មាសណាស់ ទឹកទោមនស្សត្រូចចិត្តចុះដើរចេញពីផ្ទះតាំងគុះទៅ ដល់បានពាក់កណ្ដាលផ្លូវជួបប្រទះនឹងលីយូ ហើយបាននិយាយរឿងរ៉ាវប្រាប់លីយូសព្វគ្រប់ថា "តាំងគុះមានចិត្តលោភលួចយកប្រពន្ធរបស់ខ្លួនផង ជេរប្រមាថបណ្ដេញខ្លួនថែមទៀតផង" លុះថ្លែងរឿងខ្លួនប្រាប់សព្វគ្រប់ហើយ ក៏គំនាប់លាលីយូដើរសំដៅទៅកាន់ផ្ទះ ៗ ឯលីយូបានស្ដាប់ពាក្យលីប៉ោប្រាប់សព្វគ្រប់ហើយទឹកត្រូចចិត្ត ចំដើរស្រូតរូតកស់ទៅដល់ផ្ទះតាំងគុះ ហើយចូលទៅជំពបថា លោកមានសេចក្ដីប្រាថ្នាគិតការធំដុំ

ចុះហេតុម្តេចមកតាស់ទែងនឹងលីប៉ៅ ដោយសេចក្តីមិនមានខ្លឹមសារដូច្នេះ បើលីប៉ៅបែកចិត្តចេញពីលោកហើយ លោកនឹងយកនរណាធ្វើជាកំឡាំងតទៅបាន ។ តាំងគុះឮលីយូថាដូច្នោះក៏ភ័យរន្ធត់ស្មុគចិត្តហើយថា ដែលលីប៉ៅខឹងនឹងយើងនោះ អ្នកនឹងឲ្យយើងគិតដូចម្តេចឲ្យបានស្រួលឡើងវិញ ។ លីយូជំរាបថា សូមឲ្យលោករកខ្លួនលីប៉ៅមក ហើយយកមាសប្រាក់នឹងទ្រព្យរបស់ដែលមានដំឡៃឲ្យលីប៉ៅ ហើយនិយាយល្បួងលួងលោមថ្នមចិត្តឲ្យស្រួល ប្រហែលជាលីប៉ៅនឹងមានចិត្តគិតស្រឡាញ់លោកឡើងវិញ ។ តាំងគុះស្តាប់ហើយក៏យល់ព្រមជាមួយផង ។

លុះព្រឹកឡើងតាំងគុះឲ្យបំរើទៅហៅខ្លួនលីប៉ៅមកដល់និយាយថា "ក្នុងវេលាថ្ងៃម្សិលមិញបិតាមិនសប្បាយខ្លួនមានជម្ងឺឈឺក្តៅក្រហាយសព្វសាច់ ដូចជាភ្លេចស្មារតី បានជាខឹងស្តីឲ្យកូនដូច្នេះដូច្នោះហួសទៅហើយ កូនអើយអ្នកកុំប្រកាន់ទោសបិតាឡើយ" ថាហើយលើកមាស ១០ ដញ្ជឹង ព្រៃយ៉ាងល្អ ២០ ផាប់ឲ្យលីប៉ៅៗ គំនាប់ទទួលហើយយកទៅ ។ តាំងពីថ្ងៃនោះរៀងមក លីប៉ៅតែងទៅមករកតាំងគុះតាមទម្លាប់ដូចដើម តែចិត្តនោះនៅនឹករលឹកនាងគៀវសៀនមិនមានភ្លេច ១ វេលា ។ លុះយូរមកតាំងគុះជាជម្ងឺហើយក៏ចូលទៅគាល់ព្រះចៅហៀនតេ ។ លីប៉ៅជិះសេះកាន់ខ្លួនតាមទៅជាមួយផង, ពេលដែលតាំងគុះកំពុងអង្គុយគាល់ លីប៉ៅលួចចេញទៅឡើងសេះជិះបំផាយទៅដល់ផ្ទះតាំងគុះ ចង់សេះទុក

នៅមុខផ្ទះហើយ កាន់ខ្លួនចូលទៅរកនាងតៀវសៀនខាងល្វែងក្នុង ។ នាងតៀវសៀនក្រឡេកឃើញលីប៉ូ ក៏ធ្វើជាមានចិត្តអាល័យណាស់ក៏ទាប់ ហើយថា បើយើងនឹងនិយាយគ្នាក្នុងវាំងនេះខ្លាចក្រែងតាំងតុះមកទាន់នឹងកែខ្លួនលំបាក បើដូច្នេះសូមអញ្ជើញអ្នកទៅចាំខ្ញុំឯកន្លែងត្រជាក់ក្នុងសួនផ្កា ខ្ញុំនឹងចុះទៅតាមផ្លូវនេះ ។ ឯលីប៉ូក៏ចុះទៅតាមសញ្ញា ។

នាងតៀវសៀនក៏ចុះទៅតាមលីប៉ូ ហើយអង្គុយជាមួយគ្នាក្បែរមាត់ស្រះ ក្អកបេះតែសំឡឹងមើលផ្លូវក្រែងតាំងតុះមកទាន់ ។ នាងតៀវសៀនធ្វើកលទុកបាយស្ទុះទៅឱបដងលីប៉ូ ហើយក្រាបទូញយំថា "ខ្លួនខ្ញុំជាកូនមង់អ៊ុនឪពុកខ្ញុំរាប់អានស្រឡាញ់អ្នកដូចជាកូនបង្កើត បានលើកខ្ញុំឲ្យជាភរិយាអ្នក ខ្ញុំមានសេចក្ដីត្រេកអរណាស់ ដែលមហាឧបរាជទៅទទួលយកខ្ញុំមកថា នឹងរៀបការអ្នកនឹងខ្ញុំឲ្យបានជាស្វាមីភរិយានៅជាមួយគ្នា, លុះមកដល់ផ្ទះមហាឧបរាជមិនឃើញធ្វើតាមពាក្យថា, ត្រឡប់កំហែងខ្ញុំរួមប្រវេណីដូច្នេះ ទ្រូងរបស់ខ្ញុំមានតែសេចក្ដីក្រំដំណំជានិច្ច ប្រហែលជាង ១ ខែបាយហើយ គិតថានឹងអត់ដង្ហើមឲ្យស្លាប់ទៅពុំគាប់ ព្រោះមិនទាន់បានជំរាបលាអ្នក ព្រមទាំងប្រាប់ទុក្ខដែលមានក្នុងទ្រូងខ្ញុំ ឥឡូវបានជួបហើយ ខ្ញុំសូមលាអ្នកស្លាប់វេលានេះ នឹងទ្រាំរស់នៅនាំឲ្យរងកម្មចិត្តឥតអំពើ បើខ្ញុំមិនធ្វើឲ្យអ្នកឃើញដូច្នោះ មិនពិតជាត្រង់ប្រាកដ" ថាហើយក៏ស្ទុះចុះពីលើត្រែលោតតំរង់ទៅក្នុងស្រះឲ្យស្លាប់ ។ (មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

### សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

---

រឿងអសន្តិសុខក្នុងប្រទេស តាំងពីព្រះបាទមហាសិរីវ័ន្ទឡើងសោយរាជ្យ ចេះតែមានហូរហែជាដរាបមក ៗ ខនេះជាឱកាសឲ្យប្រទេសជិតខាងសំឡឹងរកផលប្រយោជន៍ ដូចដែលធ្លាប់មានមកហើយ, ក៏តែជា គ្មានប្រទេសណាដូចប្រទេសចាម្ប៉ាទេ ៗ ចាម្ប៉ាបានតាំងខ្លួនជាគូបដិបក្ខនឹងខ្មែរ បានព្យាយាមលើកទ័ពមកវាយខ្មែរជាច្រើនលើក ដូចមានពោលមកខាងដើមជាច្រើនលើកហើយ ៗ មកក្នុងរដ្ឋកាលនេះ ចាម្ប៉ាក៏លើកទ័ពមកវាយខ្មែរទៀតយ៉ាងខ្ចូចខ្ចី ៗ

## សង្គ្រាមចាម្ប៉ាគ្រាទី ២

ក្នុងរដ្ឋកាលនេះ ប្រទេសកម្ពុជាបានទទួលគ្រោះថ្នាក់ជាយ៉ាងធ្ងន់ដោយស្នាដៃចាម្ប៉ា គឺក្នុងឆ្នាំ ព.ស. ១៦២១ ចាម្ប៉ាបានលើកទ័ពមកវាយយ៉ាងធំអស្ចារ្យ ដុតផ្ទះសំបែងអស់ជាច្រើន តែចូលក្រុងពុំបាន ដោយកងទ័ពខ្មែរទប់ជាប់ ហើយដេញថយទៅវិញ ៗ

# សង្គ្រាមចាម្ប៉ាគ្រាទី ៣

កន្លងមក ៣ ឆ្នាំ គឺក្នុង ព.ស. ១៦២៤ ប្រទេសកម្ពុជាត្រូវទទួលគ្រោះថ្នាក់ពីគ្រេត គឺត្រូវទឹកធំលិចយ៉ាងខ្លាំង ទាំងទីក្រុងយសោធរបុរៈក៏លិចដែរ ប្រជារាស្ត្រត្រូវបង់ជីវិត និងខូចខាតរបស់ទ្រព្យជាច្រើន ។ ចំណែកខាងចាម្ប៉ាកាលបានដំណឹងនេះហើយ ក៏ម្នីម្នាលើកទ័ពទូកយ៉ាងធំ មកវាយប្រទេសកម្ពុជា ប្រជូនថែមទៀត ។ វេលានោះខាងរាជការខ្មែរគ្មានអ្វីទប់ទល់ចាម្ប៉ាបានទេ ដោយហេតុ

១ – ត្រូវច្បាំងដោយទូក, ទូកចំបាំងខ្មែរក្នុងវេលានោះគ្មាន, ទូកចំបាំងដែលធ្លាប់សាងសន្សំទុកសម្រាប់ការពារប្រទេសដូចក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ២ និងព្រះបាទយសោវរ្ម័នទី ១ ជាដើមនោះ បានខូចខាតអស់ទៅហើយ ក្នុងរជ្ជកាលតៗមក ឃើញហាក់ ដូចជាធ្វេសក្នុងរឿងនេះ ទើបខ្វះប្រើ ។

២– ពួកសេនាទាហានឬពួកប្រជារាស្ត្រវេលានោះ ត្រូវទឹកធំលិចគិតតែផ្គត់ផ្គង់ជីវិតរបស់ខ្លួនរៀងខ្លួន មិនអាចនឹងមកជួយការពារបាន ។

៣ – ព្រះបាទហរិវរ្ម័នទ្រង់ព្រះជរាញ្ញសណាស់ទៅហើយផង ប្រហែលជាគ្មានអ្នកណាជាមេគំនិតគិតទប់គ្រោះថ្នាក់ ដែលហូរចូលមកយ៉ាងរួសរាន់នេះបាន ។

កាលទ្រង់ជ្រាបដំណឹងសឹកនេះហើយ ក៏ត្រាស់ឲ្យព្រះរាជវង្សានុវង្ស

នឹងពួកមន្ត្រីធំតូចខ្លះ នាំគ្នាចុះទូកតាមដែលមាន ព្រមទាំងជញ្ជូនព្រះរាជទ្រព្យដែលមានខ្លឹមសារ ហើយនឹងរបស់ស្រាលៗ ដែលល្មមដឹកជញ្ជូនយកទៅបាន ។ ព្រះកែវមរកតដែលជារបស់មង្គល ក៏ត្រូវនិមន្តចុះទូកទៅដែរ ស្រេចហើយទ្រង់ត្រាស់ឲ្យចែវ-អុំទៅសំចតនៅដើមកំពង់វែកដែលទឹកមិនបានលិច ។

កាលព្រះមហាក្សត្រិយ៍នឹងពួកបរិវារចេញផុតទៅហើយ កងទ័ពចាម្ប៉ក៏ទៅដល់ព្រះមហានគរ ។ ទ្វារព្រះមហានគរទាំង ៨ ទិស ក្នុងវេលានោះចំហ គ្មានទាហានសូម្បី ១ នាក់នៅការពារទេ ។ ទ័ពចាម្ប៉លើកចូលទៅដោយងាយ ទាហានចាម្ប៉បានទៅរុករើព្រះរាជស្ថានគ្រប់អន្លើ របស់ណាដែលត្រូវការ ក៏នាំគ្នាជញ្ជូនដាក់ទូកយកទៅ របស់ណាមិនត្រូវការក៏បំផ្លាញចោលខ្ទេចខ្ទីអស់ ស្ទើរតែគ្មានអ្វីសល់នៅ ហើយក៏លើកទ័ពត្រឡប់ទៅវិញ ។ ចាម្ប៉មានសេចក្តីឥស្សាឈ្នានីសខ្មែរជាបំផុត ក្នុងរឿងដែលខ្មែរមានសម្បត្តិជាងនឹងរុងរឿងថ្កុំថ្កើងជាង ។ ទ័ពចាម្ប៉ដែលលើកមកវាយប្រទេសខ្មែររាល់ៗដង គ្មានអ្វីក្រៅពីមកដុតបំផ្លាញផ្ទះសំបែងហើយនឹងជញ្ជូនយកទ្រព្យរបស់ទៅទេ ទំនងដូចជាទ័ពចោរប្លន់ ។

និយាយពីព្រះអាទិត្យវង្ស ក្សត្រិយ៍មហាឧបរាជរបស់ខ្មែរដែលគ្រប់គ្រងរដ្ឋតាកាវ៉ែ សឹងគង់នៅស្រីអយុធ្យា កាលទ្រង់ជ្រាបពត៌មានសឹកនឹងទឹកជំលិចព្រះមហានគរយសោធរបុរៈដូច្នេះហើយ ក៏ត្រាស់ឲ្យទាហានរៀបទូកព្រះទីនាំង នឹងទូកសម្រាប់សេនាទាហានតាមដែលមាន ហើយ

ស្តេចចុះទូកព្រះទីនាំងព្រមដោយសេនាទាហាន មកកាន់ព្រះមហានគរ ដើម្បីនឹងជួយការពារគ្រោះថ្នាក់អំពាលនោះ ។ កាលស្តេចមកដល់ជិតក្នុងនគរ ក៏បានដំណឹងថា ព្រះបាទហរិរ័ក្សព្រមដោយរាជបរិពារ ស្តេចចេញមកសំចតនៅជើងក្នុងនគរហើយ ក៏ទ្រង់ឈៀងចូលទៅថ្វាយបង្គំព្រះមហាក្សត្រិយ៍ ហើយក្រាបទូលអញ្ជើញស្តេចឲ្យទៅគង់ឯក្រុងស្រីអយុធ្យា ។ ព្រះបាទហរិរ័ក្សក៏ព្រមតាម, ក្បួនទូកព្រះទីនាំងក៏លៀនលយទៅដល់ក្រុងស្រីអយុធ្យា (១) ។

---

១ សេចក្តីគួរសង្កេតៈ ព្រះរាជពង្សាវតារក្រុងកម្ពុជាគ្រប់ៗ ច្បាប់ថា ក្រុងនគរធំត្រូវទឹកជំនន់លិចនោះក្នុងរជ្ជកាលព្រះបាទសេនករាជ ។ ហេតុដែលទឹកលិច បណ្តាលមកពីទោសដែលសម្លាប់កូនបុរោហិត ។ សេចក្តីថា សម័យមួយនោះព្រះរាជឱរសព្រះបាទសេនករាជក្រសាលរុយក្បាលទៀត ហើយកូនបុរោហិតលេងពីងពាង ។ ពីងពាងកូនបុរោហិតបានទាំសម្លាប់រុយរបស់ព្រះរាជកុមារ ព្រះនាមសីហនុ ។ ព្រះរាជកុមារទ្រង់ព្រះកន្សែង ពសៀងលួងលោមយ៉ាងណាក៏មិនព្រមស្ងៀម ។ ដរាបដល់ព្រះរាជបិតាត្រាស់ឲ្យយកកូនបុរោហិតទៅជ្រមុជទឹកសម្លាប់បង់ ។ ទោសនេះឯង ដែលបណ្តាលឲ្យទឹកលិចនគរធំ ។ ឯរឿងចំបាំងបាឡីញ៉ាន ពោលពិល ។

ចំណែកព្រះរាជពង្សាវតារច្បាប់នេះថា ព្រះមហាក្សត្រិយ៍សោយរាជ្យក្នុងវេលានោះ គឺព្រះបាទ ហរិរ័ក្សទី ៣ គ្មានព្រះរាជឱរសព្រះរាជធីតាទេ ។ រឿងរុយ - ពីងពាងគ្មានទេ មានតែរឿងទឹកធំលិច នឹងរឿងទំពាម្យ ។

យោបល់យើងថា រឿងរុយ - ពីងពាង បើទុកជាមានពិត យើងជឿជាក់ថា ព្រះមហាក្សត្រិយ៍របស់យើងនោះព្រះនាមដូចម្តេចក៏ដោយ គង់ជាមិនមានព្រះរាជហឫទ័យឃោរឃៅ ដល់ទៅសម្លាប់កូនក្មេងដែលមិនទាន់ដឹងក្តីដូច្នេះទេ ។

ព្រះអាទិត្យវង្សបានចាត់ទីកន្លែងថ្វាយគង់តាមសមគួរ រហូតដល់ទៅពួកព្រះរាជវង្សានុវង្សនូវរាជបរិពារ ក៏ទ្រង់ឲ្យចាត់ទីកន្លែងឲ្យសំណាក់អាស្រ័យទូទៅគ្រប់គ្នា ។

ក្រោយដែលព្រះមហាក្សត្រិយ៍ចេញទៅ ព្រះនគរក៏នៅចំហទទេជាយូរខែ ជាហេតុឲ្យអ្នកលោភយសបានឱកាស ខ្វល់ខ្វាយរកប្រយោជន៍ផ្ទាល់ខ្លួន ។ គ្រានោះ ប្រាកដថា មានបុគ្គល ១ នាក់ដែលគេមិនស្គាល់ឈ្មោះ តែប្រហែលជាជាតិក្សត្រិយ៍ ព្រមដោយព្រាហ្មណ៍មួយនាក់ ជាអ្នកលោភយសលើសលប់ បានផ្តើមរួបរួមសេនារេហ៍ពលបានជាច្រើនហើយ ក៏ទៅតាំងទីសំណាក់ព្រះនគរនៅខាងជើងភ្នំដងរែកដោយបំណងនឹងគ្រប់គ្រងកម្ពុជរដ្ឋ ។

ក្នុងពេលជាមួយគ្នានោះ មានព្រះរាជវង្ស ១ អង្គព្រះនាមជយវរ្ម័នកាលទ្រង់ជ្រាបហេតុនេះ ក៏ទ្រង់ឆក់យកឱកាសដ៏ខ្ចីនោះ រួបរួមសេនាពាហានច្រើនហើយ ក៏លើកចូលទៅគ្រងបល្ល័ង្កនៅក្រុងស្រីយសោធរបុរៈបានមុន ។ កាលទ្រង់ចូលទៅតាំងស៊ប់សួនហើយ ទ្រង់ក៏លើកទ័ពទៅកំចាត់អ្នកតាំងនគរនៅខាងជើងភ្នំដងរែកបង់ ។ តាមដំណឹងថា ទ្រង់សម្លាប់អ្នកម្ចាស់នគរនោះបាន ហើយស្តេចលើកទ័ពត្រឡប់មកព្រះនគរវិញ ។

(មានត)

## ប្រវត្តិរបស់អេសុប

# លោកផេង-ជើរ សាស្ត្រាចារ្យនៅអនុវិទ្យាល័យនារី ភ្នំពេញ

### ប្រែពីបារាំងមកជាខ្មែរ

(តមក)

មានសំឡាញ់របស់សង្ធុះម្នាក់ បានឮសេចក្តីអធិប្បាយដូច្នោះក៏មានវាចាថា "អ្នកបំរើរបស់លោកនេះ ចំជាមានប្រយោជន៍ដល់លោកពេក ព្រោះវាប៉ុនប្រសប់រកអ្នកឯណាស្មើគ្មាន គឺវាចេះញុំាងខន្តីសេចក្តីអត់ធន់របស់អ្នកប្រាជ្ញឲ្យតាំងនៅបាន ។ អេសុបឆ្លើយថា លោកចាំបាច់មានប្រសាសន៍ឲ្យនឿយព្រួយចំពោះរឿងនេះ ។ សង្ធុះឮសំដីដូច្នោះ មិនទាន់អស់ចិត្ត នៅចង់ចាប់លោកទៀត ក៏ប្រាប់ថា: ចូរឯងទៅរកមនុស្សណាដែលមិនចេះព្រួយនឹងអ្វីសោះ យកមកឲ្យអញឲ្យបានកុំខាន ។

ស្អែកឡើង អេសុបទៅឯទីផ្សារ ចាំគយគន់មើលមនុស្ស, លោកបានឃើញអ្នកស្រែម្នាក់ បើឈរមើលអ្វី មើលដូចគេគ្មានគិតគ្មានពិចារណា នៅព្រងើយកន្តើយដូចថ្មអ្នកតា ។ លោកនាំអ្នកនោះទៅឯផ្ទះប្រគល់ឲ្យចៅហ្វាយរបស់លោកហើយប្រាប់ថា: ហ្នឹងហើយមនុស្សមិនចេះព្រួយ ដែលលោកត្រូវការចង់ឃើញ ។ សង្ធុះប្រើប្រពន្ធឲ្យទៅដាំទឹកឲ្យក្តៅអ៊ុនៗ ហើយយកមកលាងជើងរបស់អ្នកជំណើរដោយខ្លួនឯង ។ អ្នកនេះទោះបីដឹងថាការធ្វើយ៉ាងហ្នឹងមិនគួរដល់អាត្មាទេ ក៏នៅតែស្ងៀម

បណ្ដោយតាមតែគេធ្វើដូចម្ដេចក៏ដោយ ហើយគាត់តែនឹកថា: ប្រហែលទំលាប់ស្រុករបស់គេធ្វើដូច្នេះដឹង! ។ រួចគេហៅឲ្យទៅអង្គុយត្រង់កន្លែងយ៉ាងស្អាតជាកន្លែងកិត្តិយសរបស់គេ; អ្នកស្រែនេះតែអង្គុយគ្មានប្រកែក ។ ពេលបាយ សង្ឃគិតតែពីស្ដីឲ្យចុងភៅ: សម្លប៉ុន្មាននេះតែមិនឆ្ងាញ់ទាំងអស់ មួយណាឆ្ងាញ់ល្មមទទួលបាន លោកថាប្រៃពេក មួយណាប្រៃលោកថាល្មម ។ អ្នកស្រែនោះបើសង្ឃថាអ្វីក៏ដោយគិតតែពីស៊ីពេញ ៗ មាត់ឃ្លុម ៗ មិនរវល់ថាអ្វីសោះ ។ ពេលបន្អែមគេយកនំដែលប្រគេនរបស់លោកធ្វើមកដាក់លើតុ ។ សង្ឃពោលថា: ចុះនំនេះអីក៏គ្មានឆ្ងាញ់សោះ ។ តែនំនោះឆ្ងាញ់មានឱជារសយ៉ាងក្រៃពេក ។ រួចលោកមានប្រសាសន៍ថា: ខ្ញុំមិនដែលឃើញអាណាធ្វើនំអីក៏អាក្រក់ម្ល៉េះ ត្រូវយកអ្នកដែលធ្វើនំទៅដុតភ្លើងចោល ព្រោះវាធ្វើអ្វីមិនដែលបានល្អសោះ ចូរប្រាប់ឲ្យអ្នកណាយកបាច់ឧសមក អញនឹងដុតមេចង្រៃនេះចេញ ។ អ្នកស្រែឆ្លើយថា: ឈប់ ៗ! ចាំខ្ញុំទៅយកប្រគេនរបស់ខ្ញុំមកដុតជាមួយផង កុំឲ្យពិបាកធ្វើគំនរច្រើនកន្លែង ។ សំដីរបស់អ្នកស្រែនេះ នាំឲ្យសង្ឃទាល់គំនិត ឈប់សង្ឃឹមក្នុងការយកទោសចំពោះអេស៊ុបគាំងពីថ្ងៃនេះតទៅ ។

ម្យ៉ាងទៀតមិនត្រឹមតែនាយចៅហ្វាយរបស់លោកឡើយ ដែលលោកធ្វើឲ្យមានរឿងគួរឲ្យអស់សំណើច ហើយនឹងពោលពាក្យយ៉ាង

ត្រូវឲ្យសរសើរ លោកមាននិយាយនឹងអ្នកដទៃទៀតដែរៗ សម័យមួយ អេសុបទៅផ្សារប្រទះជួបនឹងសុភាចារបុរសម្នាក់ ៗ អ្នកភ្នាក់ងាររាជការនេះ សួរលោកថា: ចុះឯងទៅណាមកណា? ៗ វេលានោះមិនដឹងជាអេសុប កំពុងតែស្ងួនចិត្តក្នុងអារម្មណ៍អ្វីៗ កំពុងតែគិតអ្វីជាប់ចិត្ត ស្រាប់តែឆ្លើយតប ទៅកេះលោកសុភាថា: ខ្ញុំមិនដឹងជាទៅណាមកណាទេ ៗ លោក សុភាស្មានជាអេសុបនិយាយកោងគ្មានសេចក្ដីគោរពកោតក្រែង ក៏ឲ្យគេ នាំលោកយកទៅដាក់គុកប្រដៅ ៗ វេលាដែលអ្នកនាំផ្លូវរៀបនឹង បញ្ចូលលោកទៅក្នុងគុក លោកនិយាយឡើងថា: ម្ដេច! លោកមិន ឃើញទេឬ? សំដីដែលខ្ញុំដំរាបលោកអម្បាញ់មិញចំពេញជាត្រូវអស់ យ៉ាង គឺខ្ញុំដឹងថាគេបញ្ជូនខ្ញុំឲ្យទៅតាមកន្លែងដែលខ្ញុំបាទត្រូវការ ៗ លោកសុភាឮសំដីប៉ុណ្ណោះក៏ឲ្យគេដោះលោកលែង ហើយនិយាយប្រាប់ សង្ធុះថា: អ្នកមានបាវម្នាក់ឈ្មោះអេសុបចំជាមានបញ្ញាក់ងវៃមែន ៗ

សង្ធុះដែលឃើញអេសុបមានប្រយោជន៍នឹងហុចកេរ្តិ៍ឈ្មោះឲ្យដល់ខ្លួន ក៏ឈប់រើឲ្យលោកដើរចេញហួសពីអាត្មា ៗ

ថ្ងៃមួយសង្ធុះនឹងកូនសិស្សទាំងឡាយរបស់គាត់នាំគ្នាផឹកស្រាលេង សប្បាយ ៗ អេសុបជាអ្នកបំរើកៀវ លុះឃើញគេផឹកខ្លាំងពេក គ្រូក៏ ស្មើគ្នានឹងសិស្ស, លោកមានប្រសាសន៍ពន្យល់ថា: ការផឹកស្រានេះមាន ៣ថ្នាក់ ទី ១ នាំឲ្យឆ្ងាញ់, ទី ២ ស្រវឹង, ទី ៣ នាំឲ្យភាពមិនដឹងខុសត្រូវ ៗ

គេនឹងសិស្សទាំងឡាយមិនអើពើនឹងសំដីរបស់លោកសោះ គិតតែនាំគ្នាផឹក ៗ សន្ធុះផឹកទាល់តែស្រវឹងវង្វេងស្មារតី ហើយអួតខ្លួនថាៈ ស្អែកនេះនឹងអាចផឹកទឹកសមុទ្រទាំងអស់បាន ៗ ពួកភ្ញៀវព្រួយព្រោះនាំគ្នាសើច ៗ សន្ធុះឆ្លើយឡើងថាៈ ទេកុំសើច! អញនិយាយមែនទែន អញហ៊ានភ្នាល់ដាក់ផ្ទះរបស់អញហ្នឹង ស្អែកប្រាកដជាអញអាចផឹកទឹកសមុទ្រទាំងអស់បាន ៗ ដើម្បីធ្វើឲ្យគេជឿចិត្ត សន្ធុះដោះចិញ្ចៀនដែលពាក់នៅដៃឲ្យគេកាន់ទុកជាបន្ទាល់ ៗ

លុះព្រឹកឡើងទៅហ្វាយរបស់លោកស្វាងពីស្រវឹង ភ្ញាក់ខ្លួនដោយបាត់ចិញ្ចៀនពីដៃដែលជាទីពេញចិត្ត ៗ លោកប្រាប់ទៅហ្វាយរបស់លោកថាៈ ចិញ្ចៀនហ្នឹងអន្តរាយហើយព្រមទាំងផ្ទះផង ព្រោះលោកបានភ្នាល់នឹងគេថា នឹងផឹកទឹកសមុទ្រទាំងអស់បាន ៗ ពេលនេះអ្នកប្រាជ្ញខាងទស្សនវិជ្ជាភ័យខ្លួន អង្វរអេសុបឲ្យជួយ តើធ្វើដូចម្ដេចនឹងដោះខ្លួនរួច? ៗ អេសុបប្រាប់ឲ្យធ្វើយដូចសេចក្ដីខាងក្រោមនេះ ÷

ដល់ពេលសន្យា ពួកមនុស្សទាំងឡាយកងស្រុកសាមូស នាំគ្នាទៅឯមាត់សមុទ្រ ដើម្បីចាំផ្ចិតផ្ចាល់នូវលោកសន្ធុះ ៗ អ្នកគ្រូភ្នាល់គិតថាឈ្នះជាប្រាកដ ៗ សន្ធុះក្រោកឈរឡើង ហើយនិយាយនៅកណ្ដាលប្រជុំជនទាំងឡាយថាៈ នែ លោក! អ្នកទាំងអស់គ្នាចាំស្ដាប់ ខ្ញុំពិតជាបាននិយាយភ្នាល់ថាអាចផឹកនូវទឹកសមុទ្រទាំងអស់មែន តែមិនមែនផឹក

ទាំងទឹកទន្លេប៉ុន្មានដែលហូរធ្លាក់មកក្នុងសមុទ្រនោះផងឡើយ ។ ហេតុនេះឈ្មោះណាដែលក្អាល់ទឹងខ្ញុំ ត្រូវបង្ខិលផ្លូវទឹកនៃទន្លេទាំងប៉ុន្មាននោះចេញ ខ្ញុំនឹងផឹកទឹកសមុទ្រឲ្យមើល ។ មនុស្សទាំងអស់នាំគ្នាកោតបញ្ញារបស់សង្ខុះដែលចេះអាចដោះខ្លួនរួចក្នុងគ្រាក្រ ។ កូនសិស្សទាំងឡាយអ្នកក្អាល់បបួលគ្នាសុំខមាទោសលោកគ្រូ ហើយទទួលសុខចិត្តយ៉មចាញ់ ។ រួចគេនាំគ្នាដង្ហែលោកគ្រូគគ្រឹកគគ្រេងត្រឡប់ទៅផ្ទះវិញ ។

ដើម្បីតាវគុណបំណាច់ អេសុបសុំចេញជាកុដ្ឋិសបុគ្គល ។ ចៅហ្វាយរបស់លោកមិនព្រមឲ្យចេញ ហើយប្រាប់ថា: ពេលនេះមិនល្អ ប៉ុន្តែណ្ហើយចុះបើចង់ចេញណាស់ អញក៏ព្រមឲ្យចេញដែរ តែឯងប្រយ័ត្នប្រផ្ទលក្ង ពេលចេញពីផ្ទះទៅ បើល្អគឺឃើញមានសត្វអន្ទូបពីរទំទន្ទឹមគ្នា បើឃើញតែមួយ គឺមុខជាមិនរួចពីធ្វើជាបាវអញទៀតឡើយ ។ អេសុបដើរចេញទៅក្រោម ។ គ្រាន់តែដល់ក្រៅរបង លោកឃើញអន្ទូបពីរទំប្រចឹកនៅពីមុខ ។ ឃើញដូច្នោះលោកប្រញាប់ត្រឡប់ចូលមកផ្ទះ ប្រាប់ចៅហ្វាយរបស់លោកថា: ខ្ញុំបានឃើញអន្ទូបពីរ ។ សង្ខុះចេញទៅរកមើល ហើយឃើញតែអន្ទូបមួយ អាមួយទៀតហើរទៅបាត់ ។ ចៅហ្វាយរបស់លោកខឹងឈ្លួលហើយនិយាយថា: អាឯងបំភ័ន្តអញជាទិច្ច ចូរអាណាយករំពាត់បន្ទាមកវាយអានេះ ។ គេកំពុងតែវាយលោក ស្រាប់តែមានមនុស្សម្នាក់មកអញ្ជើញសង្ខុះទៅស៊ីលៀង ។

(មានត)

# ពន្លឺអាស៊ីទ្វីប

La Lumières de l'Asie

## លោកស៊ុរ-អេតវាំងអារណូលដ៍ តែង

លោកញ៉យ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

(តទក)

ព្រះពោធិសត្វមាន ព្រះបន្ទូលដោយពាក្យទន់ភ្លន់ ប្រកបដោយព្រះទ័យអាណិតអាសូរពន់ពេក ៗ សភាពដ៏វិសេសវិសាលយ៉ាងនេះ ប្រកបដោយព្រះទ័យករុណានឹងសុចរិតធម៌ទ្រទ្រង់ព្រះអង្គក្នុងពេលនោះ បានជាពួកព្រាហ្មណ៍បានលះបង់ដៃ ដែលប្រឡាក់ដោយលោហិតចាកចេញពីសន្ទាន ហើយព្រះមហាក្សត្រិយ៍ចូលទៅជិតព្រះពោធិសត្វលើកព្រះហស្តធ្វើអញ្ជលិកម្មគោរពចំពោះព្រះអង្គ ៗ.

តែព្រះពោធិសត្វបានសំដែងថា: លោកមុខជាបានសេចក្ដីសុខ បើសត្វទាំងអស់មានសេចក្ដីមេត្តាករុណាគ្នាទៅវិញទៅមក ហើយបរិភោគតែរបស់បរិសុទ្ធស្អាត គ្មានប្រឡាក់ដោយលោហិត គឺគ្រាប់ដែលមានសម្បុរដូចមាស, ផ្លែឈើមានស្វាទភាពក្លី, ស្មៅដែលមានឱជារស ដែលដុះនៅពាសពេញក្នុងលោក; ទឹកដែលមាននៅលើផែនដីល្មមគ្រប់គ្រាន់ឲ្យសត្វផឹកបាន ៗ ពលភាពនៃព្រះឱស្ឋព្រះពោធិសត្វប្រកបដោយពាក្យពីរោះអស្ចារ្យ ធ្វើពួកព្រាហ្មណ៍ឲ្យជឿជាក់ច្បាស់ក្នុងចិត្ត, ត្រឡប់ជាលំទួន

ឯងទូវបូជនីយដ្ឋានដែលមានគ្រឿងសក្ការៈផុត ហើយគេកាត់ដែកដែលសម្រាប់ធ្វើពលិកម្មចោលទៅឆ្ងាយ ៗ ដល់ថ្ងៃស្អែកឡើង. ព្រះមហាក្សត្រិយ៍មានព្រះរាជឱង្ការទៅពួកអាមាត្យឲ្យស្រែកប្រកាស ក្នុងព្រះរាជអាណាចក្រ. ហើយឲ្យឆ្លាក់ឲ្យបង្គាប់ឲ្យឆ្លាក់ជាអក្សរនៅផែនថ្ម នឹងគល់សសរថា: "នេះជាព្រះរាជបញ្ញត្តិព្រះករុណា ជាម្ចាស់ជីវិតលើត្បូង: តាំងពីមុនមកដល់បច្ចុប្បន្ននេះ, គេបានពិឃាតសត្វ ដើម្បីនឹងបូជាយញ្ញ ឬបរិភោគជាអាហារ, តែពីថ្ងៃនេះតទៅ ហាមផ្តាច់មិនឲ្យសម្លាប់សត្វរស់ ឬបរិភោគសាច់សត្វ ព្រោះយើងបានយល់ថា ជីវភាពមានតែមួយ ហើយសេចក្តីមេត្តាសម្រាប់ប្រើទៅសត្វណាដែលគួរមេត្តា" ។ នេះជាព្រះរាជបញ្ញត្តិព្រះមហាក្សត្រិយ៍បានប្រកាសឡើង, ហើយតាំងពីកាលនោះមក, សត្វដែលមានជីវិតបានទទួលសេចក្តីសុខ គឺព្រះពោធិសត្វព្រមទាំងសត្វជាបរិវារព្រះអង្គ នឹងបក្សាទាំងប៉ុន្មានដែលស្ថិតនៅប្របស្ទឹងគង្គា, ជាទីដែលព្រះអង្គបានទេសនាដោយព្រះទ័យករុណាដល់សត្វទាំងនោះ នឹងព្រះស្នូរសៀងពីរោះអស្ចារ្យ ។

ព្រោះព្រះទ័យព្រះពោធិសត្វប្រកបដោយព្រហ្មវិហារចំពោះសត្វដែលមានជីវិតនៅក្នុងលោក ដែលទទួលនូវសេចក្តីសុខ - ទុក្ខដូចយើងទាំងអស់គ្នា; មានសំដែងក្នុងគម្ពីរពីបុរាណកាល, តាំងពីព្រះសម្មាសម្ពុទ្ធព្រះអង្គបានយោនយកកំណើតជាព្រាហ្មណ៍ម្នាក់នៅក្នុងមុនទ? (មុណ្ឌ:) នៅផិត

ក្ងុកតាលិទ្ធ? (ទលិទ្ធត្រាម), ក្ងុកភាគក្នុងប្រទេសលំបាកដោយគ្មានភ្លៀង, ស្រវជុះមិនទាន់ខ្ពស់ល្មមឲ្យបក្សាត្រូចប្រេចបាន, ទទួលស្លាប់មួយរំពេច; នៅតាមដងព្រៃតានុវង្ស ចេញចំហាយក្ដៅដប់ទឹករីងអស់ពីបឹងត្រពាំង, ស្មៅទីងក្រាលតារល្វៃទៅជាមានសភាពស្ងាំងក្រៀម, ហើយពួកសត្វដែលនៅក្នុងព្រៃកុំទុរគមរង្គើងផ្ទ ដោយខំស្វែងរកអាហារបរិភោគ ៗ ក្នុងពេលនោះព្រះពោធិសត្វទ្រង់បានទតយល់តាមដញ្ញាំងដែលមានចំហាយក្ដៅហុយ មានវល្លិ៍ "ទុល្ហ:" ដុះព័ទ្ធ នូវខាញីមួយស្ងាំងស្គមដោយអត់អាហារស៊ីតែទឹងមរណា, និទ្រាលើផែនសិលា, សេចក្ដីស្រេកឃ្លានបញ្ចេញឥទ្ធិពល, ចក្ខុមានរស្មីពណ៌លៃគង់, ដ័ង្ហ-ប្រសាទក្រៀមស្អុតលៀនវែងចេញពីមាត់ហាហត់ស៊ើរផុតដង្ហើម, ថ្ពាល់មានតែស្បែកជ្រួញជ្រើរ, ស្បែកមានគំនូរឆ្នូតធ្លាក់យូរយារ, តាមឆ្អឹងជំនីរដូចជាផ្ទាំងដែលពុកផុយ ដោយសារគៀងមិនអាចតុបនូវដំបូលគេ·ហដ្ឋានបាន ៗ ខ្លានោះមានកូនតូច ៗ ពីរ, ស្រេកឃ្លានអាហារ, ដើរចុះឡើង ហើយក៏ជញ្ជក់ដោះដែលគ្មានទឹកដោះមួយដំណក់ ៗ ចំណែកខាងម្ដាយវា ស្គមនៅតែឆ្អឹងខំលិទ្ធកូនទាំងពីរដោយមុទិតាចិត្ត ហើយបង្ហាញឆ្អឹងជំនិរទៅកូនទាំងនោះ ស្រេកពេកចុកណែនដល់បំពង់ក ដោយសេចក្ដីស្នេហាលើសសេចក្ដីស្រេកឃ្លានទៅទៀត ហើយជួនកាលមានស្រែកខ្ទាំងលាន់ឮរំពងដូចជាសព្ទផ្គរយកច្រមុះរុញទៅនឹងដីខ្សាច់ ៗ

ព្រះបរមពោធិសត្វ ទ្រង់ជ្រាបទតឃើញនូវខ្លានោះហើយ ទ្រង់កើតមាន
មេត្តាករុណាពន់ពេក ហេតុមានទស្សន៍ស្វែងរកនូវពុទ្ធភូមិ ហើយទ្រង់
ព្រះតម្រិះថា៖ "មានតែមធ្យោបាយមួយយ៉ាង ដើម្បីនឹងស្រោចស្រង់
សត្វសាហាវដែលនៅក្នុងព្រៃនេះ, ដល់ព្រះសុរិយាអស្តង្គត សត្វទាំងនេះ
មុខជាស្លាប់មិនខានដោយអត់អាហារ ។ គ្មានបុគ្គលអ្នកណាទោរទន់ទៅកាន់
សត្វដែលមានសភាពប្រឡាក់លោហិតជានិច្ច ហើយសត្វនេះដែលស្គាំង
ស្គម គឺមកតែពីមិនបានបរិភោគឈាម ។ ព្រោះហេតុដូចនេះ, បើ
អញឲ្យជីវិតសត្វនេះបាន ដោយហេតុថាគ្មានបុគ្គលណាទទួលទុក្ខក្រៅ
ពីអញ, ដោយសេចក្តីមេត្តាជាយ៉ាងក្រៃពេក ខ្លួនអញមុខជានឹង
សម្រេចទៅតាមបំណងក្នុងពេលនេះមិនខាន" ។ ព្រះបរមពោធិសត្វ
លុះទ្រង់ព្រះតម្រិះដូចនេះហើយ ក៏ប្រោះបង់ចោលព្រះសុពណ៌បាត្រ,
ដំបងនឹងខ្សែអំបោះពិសិដ្ឋ (Cordon Sacré) [1] ឈូតក្បាល ទាំងសំពត់
កោសេយ្យព្រស្ត្រ រួចទ្រង់ចាកចេញពីគុម្ពោតព្រៃនោះ យាងមកតាម
ដីខ្សាច់មានព្រះបន្ទូលថា៖ "នែមេខ្លាអើយ! នេះជាអាហាររបស់អ្នក" ។
ក្នុងមួយរំពេច, គ្រាន់តែខ្លាញីដែលរៀបនឹងស្លាប់នោះបញ្ចេញសព្ទស្នូរ
យ៉ាងខ្លាំង ហើយក៏លោតចេញពីគុហា ស្ទុះទៅលើព្រះពោធិសត្វ ដែល

---

១. ខ្សែអំបោះពិសិដ្ឋ គឺខ្សែអំបោះបីសរសៃវេញគួបគ្នា ដែលពួកឧត្តមវណ្ណៈតែងពាក់ជា
កិត្តិយស ។ ការដែលពាក់ខ្សែអំបោះពិសិដ្ឋនេះ គឺត្រូវឲ្យមានពិធីមួយរៀបចំជាទម្លាប់ចំពោះ
ក្មេងជំទង់ដែលមានអាយុ ៨ ឆ្នាំ ហើយគេតាំងឋានៈគ្រូជា (ទ្វិជៈ) ប្រែថា មានកំណើតពីរដង ។

ជាទុក្ករបុគ្គលដោយពេញចិត្ត, ហើយក៏យកក្រចកដែលមានពណ៌លឿងយ៉ាងមុតខ្លាំងហែកសាច់ព្រះអង្គនោះ ប្រៀបដូចជាព្រះខ័នមានសភាពគោងស្រួច ហើយក៏បរិភោគនូវព្រះពោធិសត្វស្រោចដោយលោហិតពាសពេញព្រះអង្គ ហើយខ្យល់អស្សាសបស្សាសនៃសត្វសាហាវនោះបញ្ចេញចំហាយក្តៅដូចភ្លើងលាយជាមួយគ្នានឹងសព្ទថ្ងូរនៃព្រះទ័យព្រះករុណារបស់ព្រះពោធិសត្វ គួរឲ្យស្ញប់ស្ញែងពន់ពេក ។

នេះហើយជាករុណាទិគុណនៃព្រះពោធិសត្វ ហើយពីកាលមុននោះទៅទៀត ព្រះអង្គបានធ្វើពលិកម្មចំពោះទេវតាឥន្ទ្រព្រហ្ម ដោយសេចក្តីមេត្តាករុណាជាអនេកប្រការ ។ មួយទៀតក្នុងពេលនោះព្រះបាទពិម្ពិសារទ្រង់បានសវនាយល់ច្បាស់នូវរាជវង្សព្រះពោធិសត្វ ព្រមទាំងកិច្ចដ៏ឧត្តមក្នុងការស្វះស្វែងរកធម៌; បានអង្វរឲ្យព្រះអង្គគង់នៅទីក្រុងនេះ ហើយក៏មានព្រះរាជឧង្ការថា: "ឱ ទ្រង់មានឋានៈជាព្រះរាជបុត្រ! ទ្រង់មិនគួរមករងលំបាកអត់ឃ្លានដូចនេះទេ; ព្រះហស្តទ្រង់សមនឹងកាន់ព្រះទម្រង់គទាវុធ (Xeptre), មិនត្រូវកាន់អំបែងសូមទានគេទេ ។ សូមទ្រង់នៅនឹងយើងទាល់តែអស់ជីវិត, យើងគ្មានព្រះរាជបុត្រគ្រងរាជ្យសោះ ហើយសូមទ្រង់ធ្វើជាគ្រូបាធ្យាយបង្រៀននូវគតិបណ្ឌិតឲ្យប្រជារាស្ត្ររបស់យើងស្វាធ្យាយក្នុងព្រះរាជអាណាចក្រ; ទ្រង់នៅក្នុងប្រាសាទខ្ញុំ ហើយខ្ញុំនឹងរកនាងខត្តិយានីមួយថ្វាយ" ។ (មានត)

កម្លាំងនៃពាក្យព្រះពុទ្ធ

# ឃុនបណ្ណានុរក្ស ប៊ូ - ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

---

ពាក្យព្រះពុទ្ធមានកម្លាំងខ្លាំងជាងខ្យល់ព្យុះដ៏ធំ អាចធ្វើមនុស្សប្រុសស្ត្រី ឲ្យបែកបាក់បាក់គ្នាទៅជាពួក ៗ បាន ដូចរឿងសត្វហង្សខ្ទួនមួយក្បាលពីរ ដែលមានក្នុងពាកណសិរជជាតក បញ្ញាសនិបាត ថា:

ឯកស្មឹ កិរ សមយេ ភទ្ទកប្បេ កស្សបសម្មា-សម្ពុទ្ធសាសនេ តទា ឯកា ឥត្ថី សាមិកេន អញ្ញ-មញ្ញំ បដិពទ្ធចិត្តា អតិវិយ សិនេហាបវិសុទ្ធចិត្តា ហោតិ ។

កិរ បានឮមកថា សម័យមួយ ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ព្រះអង្គបានត្រាស់ឡើងក្នុងភទ្ទកប្បនេះ គ្រានោះមានស្ត្រីម្នាក់ មានចិត្តប្រតិព័ទ្ធស្រឡាញ់ស្មោះត្រង់គ្នានឹងស្វាមីនៃខ្លួនណាស់ ៗ ថ្ងៃមួយ ស្ត្រីនោះធ្វើសក្ការបូជាប្រគេនបិណ្ឌបាតដល់ព្រះសង្ឃមានព្រះពុទ្ធអង្គជាប្រធាន ហើយតាំងសេចក្ដីប្រាថ្នាថា " ខ្ញុំទៅៈកើតក្នុងភពនានា សូមឲ្យខ្ញុំលែងកើតជាស្ត្រី. ឯស្វាមីនៃខ្ញុំសូមឲ្យបានជាបងប្រុសជាទីស្រឡាញ់ស្មាលស្និទ្ធនឹងខ្ញុំ: មួយៈទៀត បើយើងខ្ញុំទាំងពីរនាក់ទៅកើតជាសត្វតិរច្ឆាន សូមឲ្យខ្ញុំទាំងពីរនាក់មានសរីរាង្គកាយជាប់ជាមួយគ្នាតែក្បាលសូមឲ្យបែកចេញពីគ្នា " ។ សម្ដេចព្រះបរមសាស្ដាទ្រង់ធ្វើអនុមោទនា

រួចហើយ ទើបស្ដេចយាងត្រឡប់ទៅកាន់វិហារវិញជាមួយនឹងភិក្ខុសង្ឃជាពុទ្ធបរិវារ ។

តាំងពីវេលានោះមក ស្វាមីនិងភរិយាទាំងពីរនាក់នោះមានជីវិតរស់នៅក្នុងមនុស្សលោកអស់កាលជាយូរ, លុះដល់ក្ស័យជីវិតហើយ ដោយផលបុញ្ញកម្មនេះនាំទៅឲ្យកើតជាកុមារក្នុងត្រកូលមហាសេដ្ឋីមួយជាតិ, ក្នុងត្រកូលព្រាហ្មណ៍មហាសាលមួយជាតិ, ក្នុងត្រកូលខត្តិយមហាសាលមួយជាតិ ។ -កុមារទាំងពីរនាក់នោះសម្រាលមកជាមួយគ្នាជាកូនភ្លោះ, កុមារដែលសម្រាលមកមុនជាបង, កុមារដែលសម្រាលមកក្រោយជាប្អូន, កុមារទាំងពីរនាក់នេះស្រឡាញ់គ្នាខ្លាំងណាស់ ។

លុះកុមារទាំងពីរនាក់នោះក្ស័យជីវិតហើយ បានទៅកើតជាសត្វហង្សមាស អាស្រ័យនៅក្នុងស្រះឈូកនាព្រៃហិមពាន្ត ។ ហង្សទាំងពីរនោះមានខ្លួនជាប់គ្នា ឯក្បាលបែកចេញពីគ្នាជាពីរ ។ ហង្សក្បាលពីរនោះមានចិត្តគំនិតស្មើគ្នា នឹងទៅរកស៊ីទីកន្លែងណាក៏ព្រមព្រៀងចិត្តគ្នាទៅ មិនដែលឈ្លោះទាស់ទែងខ្វែងគំនិតគ្នាឡើយ ។

ថ្ងៃមួយ មានព្រានព្រៃម្នាក់គាប់ទៅដល់កន្លែងដែលហង្សនៅនោះ បានឃើញហង្សមាសក្បាលពីរតួខ្លួនជាប់គ្នាដូច្នោះ ក៏នឹកអស្ចារ្យក្នុងចិត្ត ទើបត្រឡប់មកក្រាបទូលព្រះបាទពារាណសីឲ្យទ្រង់ជ្រាប ។ គ្រានោះព្រះពោធិសត្វសោយព្រះជាតិជាព្រះបាទពារាណសី ព្រះអង្គបានទ្រង់

ព្រះសណ្តាប់សេចក្តីនោះហើយ ទ្រង់ប្រោសប្រទានព្រះរាជទ្រព្យនឹងស្បៀងអាហារដល់នាយព្រានហើយត្រាស់ថា "បើអ្នកទៅយកហង្សមាសនោះមកឲ្យយើងបាន យើងនឹងឲ្យសម្បត្តិដល់អ្នកច្រើនជាងនេះទៅទៀត" ។

នាយព្រានព្រៃទទួលព្រះរាជតម្រាស់ហើយ ក៏ក្រាបថ្វាយបង្គំលាកាន់យកមេណ្ឌាសិទ្ធិចេញចាកព្រះនគរចូលទៅក្នុងព្រៃហិមពាន្ត ចាប់ហង្សមាសក្បាលពីរនោះបានដោយឧបាយនៃខ្លួនហើយ យកមកថ្វាយព្រះបាទពារាណសី ។ ទ្រង់ពេញព្រះទ័យបានព្រះរាជទានទ្រព្យនឹងស្រុកសួយឲ្យនាយព្រាន ព្រះអង្គទ្រង់ទទួលយកហង្សមាសដោយព្រះហស្ត ហើយប្រទានឲ្យអគ្គមហេសីយកទៅចិញ្ចឹមរក្សាទុក ។ គ្រានោះ ក្បាលហង្សទាំងពីរមានរស្មីភ្លឺដូចមាស បន្លឺសំឡេងពីរោះជាប់ចិត្ត ។ ព្រះរាជទេវីសព្វព្រះទ័យណាស់ ត្រាស់បង្គាប់ឲ្យដាក់ក្នុងក្រងមាស ប្រទានលាជទឹកឃ្មុំដាក់ថាសមាសឲ្យហង្សនោះស៊ីសព្វថ្ងៃ ។

ចំណេរកាលក្រោយមក ព្រះរាជទេវីក្រាបទូលព្រះបាទពារាណសីថា "ហង្សមាសក្បាលពីរខ្លួនជាប់គ្នាតែមួយនោះ ប្រសិនបើរកឲ្យដាច់ចេញពីគ្នាបាន, ហង្សមួយនឹងទុកចិញ្ចឹមក្នុងព្រះរាជនិវេសន៍ ហង្សមួយនឹងឲ្យយកទៅទុកក្នុងសួនសត្វសម្រាប់ឲ្យមហាជនមើលលេង" ។ ព្រះបាទពារាណសីទ្រង់យល់ព្រមតាមព្រះរាជទេវី ទើបបង្គាប់ឲ្យអាមាត្យទាំង

ឡាយមកប្រជុំគ្នាហើយត្រាស់សួរថា "អ្នកណាអាចនឹងបំបែកហង្សក្បាលពីរនេះឲ្យបែកចេញពីគ្នាជាខ្លួនពីរបាន យើងនឹងឲ្យរង្វាន់ដល់អ្នកនោះ" ។ អាមាត្យម្នាក់ឈ្មោះសវៃក្តង៖ បាយដែលនឹងបំបែកហង្សឲ្យទៅជាខ្លួនពីរបាន ក៏ក្រាបទូលព្រះរាជាសូមទទួលយកអាសានឹងធ្វើថ្វាយ ។ ព្រះរាជាទ្រង់ព្រះរាជទានទ្រព្យជារង្វាន់ ហើយប្រគល់ហង្សមាសឲ្យអាមាត្យនោះយកទៅ ។ អាមាត្យនោះ ទទួលយកហង្សទៅចិញ្ចឹមរក្សាទុកក្នុងផ្ទះរបស់ខ្លួន ។

ចំណេរកាលតាំងក្រោយមក ថ្ងៃមួយ អាមាត្យនោះចូលទៅគាល់ព្រះមហាក្សត្រហើយវិលមកផ្ទះវិញ ននខ្សឹបដិតក្បាលហង្សម្ខាងនិយាយខ្សាវ ៗ ធ្វើដូចជាប្រាប់រឿងស្ងាត់កំបាំងហើយចៀសចេញទៅ ។ ចំណែកហង្សម្ខាងទៀតសង្ស័យ ក៏សួរហង្សជាសំឡាញ់ថា "អម្បាញ់មិញនេះអាមាត្យខ្សឹបប្រាប់អាថ៌កំបាំងអ្វីនឹងអ្នក ? ចូរប្រាប់ឲ្យយើងដឹងផង" ។ - សំឡាញ់! ខ្ញុំគ្រាន់តែឮគេនិយាយ ប៉ុន្តែមិនដឹងគេប្រាប់រឿងអ្វីទេ ខ្ញុំស្តាប់មិនច្បាស់សោះ ។ - សំឡាញ់! ខ្ញុំមិនជឿអ្នកទេ រឿងនេះខ្ញុំបានឃើញច្បាស់នឹងភ្នែកខ្ញុំ អ្នកមើលងាយខ្ញុំហើយ ខ្ញុំរាប់អានថាជាមិត្រសំឡាញ់មកយូរដល់ប៉ុណ្ណោះ ដោយសំគាល់ថាចិត្តស្មោះត្រង់នឹងគ្នា អ្នកស្មានថាខ្ញុំដេកលក់មិនដឹងខ្លួនបានជាហ៊ាននិយាយប្រាប់មនុស្សដទៃឲ្យគេដឹងចិត្តអស់ ចិត្តអ្នកវៀចមិនស្មោះត្រង់នឹងខ្ញុំទេ, ពីថ្ងៃនេះទៅខ្ញុំលែងទុកចិត្តអ្នកហើយ ។

ហង្សម្នាក់ទៀតនិយាយប្រាប់ដូចម្ដេច ក៏ហង្សម្នាក់នោះមិនជឿសោះ ចេះតែបែកចិត្តចេញពីគ្នាកាន់តែខ្លាំងឡើង ៗ កន្លងមកពីរបីថ្ងៃ អាមាត្យនោះបានទៅឱនខ្សឹបខ្សៀវក្បែរត្រចៀកហង្សម្នាក់ទៀត ពុំតែខ្សាវៗ មិនច្បាស់សេចក្ដីថាជាអ្វី ធ្វើអាការដូចកាលទៅឱនខ្សឹបនឹងហង្សមុននោះ ៗ ហង្សម្នាក់សាកសួរទៅ, ហង្សម្នាក់ក៏ប្រាប់ដំណើរដូចគ្នាពីលើកមុន ៗ ហង្សទាំងពីរលែងទុកចិត្តគ្នាលែងជឿគ្នាទៅវិញទៅមក កើតទៅជាឈ្លោះប្រកែកធំដុំឡើងនិយាយគ្នាថា " តាំងពីយូរយារណាស់មកហើយ សូម្បីមានទោសទុស្សគ្នឹងមិនត្រូវចិត្តឬក៏ក្ដាំងក្ដាត់យ៉ាងណាក្ដី យើងមិនដែលធ្វើអ្វីដល់គ្នាទេ ឥឡូវនេះអ្នកប្រកាន់យកពាក្យសំដីរបស់មនុស្សដែលទើបនឹងមកជួបតែមួយរំពេចប៉ុណ្ណោះ ក៏ត្រឡប់ជាកាត់ចោលសេចក្ដីល្អដែលមានយូរណាស់មកហើយ តាំងពីថ្ងៃនេះទៅអ្នកកុំនិយាយនឹងយើងទៀតឡើយ" ៗ ហង្សទាំងពីរឈ្លោះប្រកែកគ្នាកាន់តែតឹងសំឡេងខ្លាំងឡើងហូតដល់ដៅប្រទេចគ្នា ហើយទទះស្លាបប្រចឹកគ្នា ៗ ដោយអំណាចសេចក្ដីក្រោធខឹងខ្លាំងពេក សរីរកាយនៃហង្សក៏បែកចេញជាពីរផ្នែក ៗ

អាមាត្យនោះឃើញហើយក៏នាំយកហង្សទាំងពីរទៅថ្វាយព្រះមហាក្សត្រ, ព្រះអង្គទតឃើញក៏មានព្រះទ័យសោមនស្សណាស់ ទើបព្រះរាជទានទ្រព្យនឹងស្រុកសួយឲ្យអាមាត្យ ហើយទ្រង់ព្រះរាជទានសត្វហង្ស

មួយឲ្យចិញ្ចឹមទុកក្នុងព្រះរាជនិវេសន៍ ហង្សមួយទៀតឲ្យយកទៅចិញ្ចឹមទុកក្នុងសួនសត្វ រួចព្រះអង្គត្រាស់សួរអាមាត្យនោះថា "អ្នកធ្វើឧបាយដូចម្ដេចបានជាហង្សបែកខ្លួនចេញពីគ្នាទៅជាពីរបាន" ។ អាមាត្យក្រាបទូលតាមអាការដែលខ្លួនធ្វើឲ្យទ្រង់ជ្រាបគ្រប់ប្រការ ។

ព្រះបាទពារាណសីទ្រង់ព្រះសណ្ដាប់សេចក្ដីនោះហើយ ក៏មានព្រះទ័យសង្វេគ ត្រាស់ថា "ឱគួរឲ្យស្ដុតប័ក្ដណាស់! ហង្សមាសក្បាលពីរខ្លួនជាប់គ្នាតែមួយ ជាសំឡាញ់ស្នាលស្និទ្ធនឹងគ្នាខ្លាំងដល់ម្ល៉េះ កាលបើមានអ្នកដទៃទៅនិយាយញុះញង់ឲ្យបែកបាក់គ្នា ក៏ប្រកាន់យកសំដីដែលញុះញង់នោះជាអារម្មណ៍ មិននឹកនាដល់ការរាប់អានស្រឡាញ់គ្នាមកយូរហើយ ត្រឡប់ទៅជាបែកចិត្តចេញពីគ្នាបាន, នឹងបាច់និយាយទៅថ្វី ដល់ហេតុដទៃៗ សូម្បីប្រជាជនទាំងពួងដែលឥតគំនិតមិនបានគិតពិចារណា ប្រកាន់យកតែពាក្យដែលគេនិយាយញុះញង់នោះជាធំហើយ ក៏មុខជាបែកចិត្តពីគ្នាមិនខានឡើយ ។

ឯមនុស្សដែលបែកចិត្តគំនិតចេញពីគ្នាមានច្រើនប្រភេទ គឺពួកខ្លះបែកគ្នាដោយការប្រទូសរ៉ាយគ្នា ពួកខ្លះបែកគ្នាដោយសេចក្ដីក្រោធខឹង, ពួកខ្លះបែកគ្នាដោយលាភសក្ការៈ ឬដោយសេចក្ដីស្រឡាញ់នាយចៅហ្វាយរបស់ខ្លួនហើយជួយកាន់ជើង, ពួកខ្លះបែកគ្នាដោយសារដណ្ដើមធ្វើរាជកិច្ច, ពួកខ្លះបែកគ្នាដោយសារមានពលពាហនៈដែលបែកខ្ញែកគ្នា

ឬដែលឥតបញ្ញាគិតពិចារណា, ពួកខ្លះបែកគ្នាព្រោះដណ្តើមយកស្រុកទេសស្រែចំការភូមិផ្ទះគ្នា ឬដណ្តើមយកគោក្របីដំរីសេះខ្ញុំប្រុសស្រីគ្នា, ពួកខ្លះបែកគ្នាព្រោះមិនដឹងគុណឧបការៈ ដែលធ្លាប់មានដល់គ្នាជាយូរមកហើយ, ពួកខ្លះប្រមូលផ្តុំរឿងបន្តិចបន្តួចបង្កឡើងឲ្យទៅជាច្រើនធំប៉ុនភ្នំ ធ្វើគុណច្រើនដែលមានមកហើយឲ្យវិនាសថយតិចទៅ ៗ មនុស្សអ្នកជឿស្ដាប់ពាក្យដែលគេនិយាយញុះញង់ហើយ កាលមុនដំបូងគ្រាន់តែធ្វើឲ្យកើតទោសបន្តិចបន្តួចទេ លុះយូរទៅចេះតែពូតផ្តុំឲ្យកើតច្រើនឡើងពល់វេលា ដូចអ្នកបង្ហូរទឹក មុនដំបូងតែជីកប្រឡាយទឹកឲ្យហូរតែបន្តិច ៗ លុះយូរទៅទឹកនោះហូរច្រោះជ្រៅធំចេញទៅទៀត ទាល់តែក្លាយទៅជាព្រែកមួយយ៉ាងធំដូច្នោះ ៗ មួយទៀតបុគ្គលអ្នកប្រព្រឹត្តញុះញង់គេដោយបិសុណាវាចា ធ្វើស្មារតីឲ្យដូចជាសម្រាមសម្រាប់បង្កាត់ភ្លើង ឃើញគេកាត់ខុសតែបន្តិចបន្តួចក៏ចេះតែបង្កបង្កើតឡើងបន្តិចម្តង ៗ ទាល់តែធ្វើឲ្យគេវិនាសខ្ទេចខ្ទីដូចទឹកដែលហូរទៅកាន់ស្ទឹងបឹងត្រពាំង រមែងនាំរបស់ផ្សេង ៗ មានស្មៅទឹងដើមឈើជាដើមដែលដុះនៅក្បែរច្រាំងនោះឲ្យបាក់សោតទៅតាមផង ៗ អ្នកដែលបែកបាក់គ្នារមែងធ្វើខ្លួនទីជំរកដទៃឲ្យវិនាស, មនុស្សដែលមិនបានពិនិត្យពិចារណាចេះតែជឿសំដីគេញុះញង់ ឈ្មោះថានាំយកហេតុខាងក្រៅមកទុកក្នុងចិត្ត . រមែងមានសេចក្តីវិនាសធំ ៗ

(មានត)

# រឿងសត្វចាំសីល

សសបណ្ឌិតជាតក បុចិមន្ទូវគ្គ ចតុក្កនិបាតវណ្ណនា

## ព្រះគ្រូសាសនវង្ស គុយ-ស៊ូត្រ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

### រៀបរៀង

រឿងនេះ ព្រះបរមសាស្ដានៃយើងកាលគង់នៅវត្តជេតពន ទ្រង់សំដែងប្រារព្ធនឹងកុដុម្ពិកម្នាក់ដែលនៅក្នុងក្រុងសាវត្ថី ។ កុដុម្ពិកនេះជាអ្នកមានសទ្ធាបានតាក់តែងធ្វើមណ្ឌបរួចហើយនិមន្តព្រះសង្ឃ ៥០០ អង្គ មានព្រះពុទ្ធជាប្រធាន មកថ្វាយបរិក្ខារទាន គ្រប់មុខឥតខ្វះអ្វី ឡើយ ។ លុះរួចកលកត្តកិច្ច ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាកថា ថា: " ការឲ្យទានបែបនេះ ត្រូវតាមត្រកូលអ្នកប្រាជ្ញអំពីជំនាន់ដើម ដែលអាចលះជីវិតឲ្យជាទានដល់សព្វទាំងពួងបាន " ហើយទ្រង់លើករឿងនោះមកសំដែងដូចតទៅនេះ :

ក្នុងកាលកន្លងទៅហើយ ព្រះរាជាព្រះនាមព្រហ្មទត្ត សោយរាជ-សម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះ ព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ នៅអាស្រ័យក្នុងដងព្រៃ ១ ដែលមានជើងភ្នំព័ទ្ធម្ខាង មានស្ទឹងម្ខាង ម្ខាងទៀតមានស្រុកបច្ចន្តគ្រាម ។ ក្នុងអរញ្ញប្ប-ទេសនោះ មានសត្វស្វា ១ ចចក ១ និងភេ ១ ជាសំឡាញ់គ្នា បាននៅ

រួមជាមួយនឹងសត្វទន្សាយដែរ សុទ្ធតែជាបណ្ឌិត គឺជាសត្វចេះដឹង, តែង នាំគ្នាស្វែងរកអាហារតាមគោចរដ្ឋានតែរៀងៗខ្លួន លុះវេលាថ្ងៃរសៀល ល្ងាចទើបមកជួបជុំគ្នា ។ ចំណែកទន្សាយបណ្ឌិតវិញតែងពន្យល់ធម៌អាថ៌ ឲ្យឱវាទដល់សត្វទាំង ៣ ថា "អ្នករាល់គ្នាត្រូវឲ្យទាន ត្រូវរក្សាសីល ត្រូវធ្វើឧបោសថកម្មកុំបីខានឡើយ" ។ សត្វទាំងនោះ លុះទទួលឱវាទ ហើយ ក៏ចូលទៅដេកសម្ងំនៅក្នុងគុម្ពឈើ ជានិវាសនដ្ឋានតែសព្វខ្លួន ៗ

ថ្ងៃមួយជាខាងក្រោយមក ទន្សាយបណ្ឌិតក្រឡេកមើលទៅលើ មេឃបានឃើញព្រះចន្ទ្រ ក្នុងផ្ទៃអាកាស ក៏ដឹងច្បាស់ថា ស្អែកនេះ ជាថ្ងៃឧបោសថ ទើបហៅសត្វទាំងនោះមកប្រាប់ថា "ស្អែកនេះ ជាថ្ងៃ ត្រូវរក្សាឧបោសថ អ្នកទាំងអស់គ្នាចូរសមាទានសីលហើយរក្សាឧបោ-សថ ព្រោះអ្នកដែលរក្សាសីល ហើយឲ្យទានផង រមែងបានផលច្រើន ហេតុដូច្នោះ កាលបើមានស្មូមណាមួយដើរមកដល់ អ្នកត្រូវតែឲ្យអាហារ ដែលមានឱជារស" ។ សត្វទាំង ៣ នោះទទួលព្រមតាម ហើយក៏ទៅ ដេកដេកនៅក្នុងកន្លែងរបស់ខ្លួនទីទៃពីគ្នា ។ លុះព្រឹកព្រាងឡើង បណ្ដា សត្វទាំង ៤ នោះ សត្វភេក៏ត្រាច់ទៅរកអាហារពីព្រលឹម ដើរអើតងើត ៗ សំដៅទៅកាន់ឆ្នេរទន្លេគង្គា ។ គាប់ជួនពេលនោះ មានព្រានសន្ទូច ម្នាក់បានត្រីឆ្ពិន ៧ កាត់យកវល្លិដោតជាចង្អោមកប់ទុកក្នុងដីខ្សាច់ទៀប មាត់ច្រាំងទន្លេគង្គា ហើយដើរចុះទៅយកត្រីខាងក្រោមទន្លេទៀត ។

ឯភេលុះធុំក្លិនត្រី ក៏កកាយដីខ្សាច់អូសត្រីនោះយកមកហើយស្រែករំពង ៣ ដងថា "ត្រីនេះមានម្ចាស់ឬទេ?" កាលមិនឃើញមានម្ចាស់ ក៏នាំយកទៅទុកក្នុងគុម្ពឈើជាទីលំនៅ រង់ចាំកាលគួរនឹងបរិភោគ រួចដេកពិចារណាសីលរបស់ខ្លួនសិន ។ ឯសត្វចចកបានចេញទៅរកអាហារដែរ ស្រាប់តែទៅពើបពះប្រទះនឹងសាច់ចំនួចពីរចង្កាក់ តាំងទន្សងឆ្អើរ ១ នឹងទឹកដោះខាប់ ១ ដប ដែលអ្នកស្រែម្នាក់គេដាក់ក្នុងខ្ទម ក៏ស្រែកបន្លឺ ៣ ដងថា "របស់តាំងនេះមានម្ចាស់ឬទេ?" លុះមិនឃើញមានម្ចាស់ ក៏ពាក់ខ្សែដែលចងដបទឹកដោះឮដក មាត់ពាំសាច់ចំនួចនឹងទន្សងឆ្អើរ យកទៅទុកក្នុងគុម្ពឈើជាលំនៅខ្លួន គិតថាចាំដល់ពេលគួរសឹមអញបរិភោគ ហើយដេកពិចារណាសីលរបស់ខ្លួនដែរ ។ ឯពានរវិញក៏ចូលទៅកាន់ដងព្រៃ បេះបានផ្លែស្វាយទុំយកមកទុកក្នុងគុម្ពៈឈើជាទីលំនៅខ្លួនហើយគិតថា "អញចាំដល់ពេលទើបរិភោគ" ក៏ដេកពិចារណាសីលរបស់ខ្លួនដែរ ។ ថ្ងៃឯទន្សាយបណ្ឌិត គិតថា "ចាំដល់ពេលស្រួលអញនឹងចេញទៅស៊ីស្មៅចិញ្ចៀន តែបើមានពួកស្មូមដើរមកកាន់សំណាក់នៃអញ ៗ នឹងឲ្យស្មៅដល់គេដូចម្ដេចកើត សូម្បីតែល្ងឬអង្ករជាដើម របស់អញក៏គ្មានដែរ, ប៉ុន្តែប្រសិនបើមានស្មូមដើរមកមែន អញនឹងឲ្យសាច់សរីរៈរបស់អញពុំខានឡើយ" ។ ដោយអំណាចតេជះសីលរបស់ព្រះពោធិសត្វ លំនៅនៃសក្កទេវរាជក៏ក្ដៅ ។

សេចក្តីដំណាលថា: ហេតុដែលបណ្តាលឲ្យក្តៅដល់ពិភពសក្កទេវរាជ មាន ៤ យ៉ាងគឺ: ដោយសក្កទេវរាជអស់អាយុ១, ដោយសក្កទេវរាជអស់បុណ្យ១, ដោយសត្វឯទៀតមានអានុភាពធំប្រាថ្នាឋានៈនៃទេវរាជ១ ដោយតេជះសីលរបស់ពួកសមណព្រាហ្មណ៍អ្នកប្រតិបត្តិធម៌១, កាលនោះពិភពសក្កទេវរាជក៏ក្តៅ ។

លំដាប់នោះ សក្កទេវរាជពិចារណាមើលទៅ ក៏បានជ្រាបហេតុសព្វគ្រប់ ទើបចង់ល្បងមើលស្តេចទន្សាយនោះ ហើយនិម្មិតខ្លួនជាព្រាហ្មណ៍ម្នាក់ ដើរចូលទៅឈរនៅជិតកន្ទេនគេជាមុន ។ ក្សណនោះសត្វគេឃើញហើយក៏សួរថា "តាព្រាហ្មណ៍អើយ! តាអញ្ជើញមកមានការអ្វី?" ។ ឥន្ទព្រាហ្មណ៍តបថា "ម្នាលអ្នកជាបណ្ឌិត! ខ្ញុំមកនេះប្រាថ្នាតែអាហារ ប្រសិនបើបានបរិភោគតែបន្តិចបន្តួច ខ្ញុំនឹងរក្សាឧបោសថ ហើយធ្វើសមណធម៌ដែរ" ។ គេឆ្លើយថា "ប្រពៃហើយលោកតា! ខ្ញុំអាចជូនពិសាបាន" ហើយនិយាយចចាកអាពកជាមួយនឹងព្រាហ្មណ៍នោះដោយគាថា ថា:

សត្ត មេ រោហិតា មច្ឆា ឧទកា ថលមុព្ភតា
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វសាតិ ។

"តាព្រាហ្មណ៍អើយ! ខ្ញុំមានតែត្រីថ្ពិន ៧ ដែលព្រានសន្ទូចស្រង់ពីទឹកមកទុកលើគោក ខ្ញុំមានតែរបស់នេះ សូមអញ្ជើញតាពិសាមច្ឆាហារនេះ ហើយនៅធ្វើសមណធម៌ក្នុងដងព្រៃចុះ" ។

ខណៈនោះ ឥន្ទព្រាហ្មណ៍តបវិញថា "ល្អហើយទៅគា! ចូរទុកទៅសិនចុះ" ហើយគាត់ដើរហួសទៅកាន់លំនៅសត្វចចកទៀត ។ ឯចចកលុះឃើញព្រាហ្មណ៍ទៅដល់ ក៏ពោលពាក្យស្រួសរាយមករកដោយគាថាថា:

ធុរស្ស មេ ខេត្តបាលស្ស រត្តិ ភត្តំ អបាភតំ
មំសសូលា ច ទ្វេ គោធា ឯកញ្ច ទធិវារកំ
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វសាតិ ។

"គាព្រាហ្មណ៍អើយ! ភត្តាហារដែលគេនាំមកក្នុងពេលយប់ គឺសាច់ចំនួចពីរចង្កាក់, ទន្សងផ្អើរ ១ នឹងទធិ ១ ដប របស់អ្នករក្សាស្រែឯណោះដែលនៅជិតខ្ញុំ ខ្ញុំមានតែរបស់ប៉ុណ្ណោះ សូមអញ្ជើញពិសាវត្ថុទាំងនេះ ហើយនៅធ្វើសមណធម៌ ក្នុងដងព្រៃចុះ" ។

ឥន្ទព្រាហ្មណ៍គ្រាន់តែពោលពាក្យទទួលអំណរហើយ ក៏ដើរហួសទៅកាន់លំនៅសត្វស្វាទៀត ។ ឯពានរកាលឃើញព្រាហ្មណ៍ទៅដល់ ក៏និយាយសំណេះសំណាលមករក ដោយគាថា ថា:

អម្ពបក្កុទកំ សីតំ សីតច្ឆាយំ មនោរមំ
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វសាតិ ។

"គាព្រាហ្មណ៍អើយ! ខ្ញុំមានតែវត្ថុប៉ុណ្ណោះ គឺផ្លែស្វាយទុំ ទឹក

ត្រជាក់ ទឹងម្លប់ឈើត្រជាក់ ជាទីរីករាយចិត្ត សូមអញ្ជើញតាពីសារបស់ទាំងនេះ ហើយនៅធ្វើសមណធម៌ក្នុងដងព្រៃចុះ" ។

លំដាប់នោះ តាព្រាហ្មណ៍ពោលពាក្យទទួលអំណររួចហើយក៏ដើរហួសទៅដល់លំនៅនៃទន្សាយបណ្ឌិតទៀត ហើយថ្លែងប្រាប់អំពីសេចក្តីត្រូវការចង់បរិភោគអាហារ ហើយទឹងនៅរក្សាឧបោសថសីល ។ ឯទន្សាយបណ្ឌិត កាលឮពាក្យនោះហើយនិយាយថា "តាព្រាហ្មណ៍អើយ! តាអញ្ជើញមកកាន់សំណាក់របស់ខ្ញុំ ដើម្បីអាហារនេះ ជាការប្រពៃហើយ, ដ្បិតក្នុងថ្ងៃនេះខ្ញុំចង់បានឲ្យទាន ដែលខ្ញុំមិនធ្លាប់ឲ្យ តែបើតាជាអ្នករក្សាសីល មិនធ្វើបាណាតិបាតទេ ចូរតាទៅដញ្ជូនឧសមកបង្កាត់ភ្លើង ឲ្យបានជារងើកហើយមកប្រាប់ខ្ញុំវិញ ខ្ញុំនឹងលោតទំលាក់ខ្លួន ត្រង់កណ្តាលរងើកភ្លើងនោះ, កាលបើសរីរៈសាច់របស់ខ្ញុំឆ្អិនហើយ ចូរតាយកមកពីសា ហើយធ្វើសមណធម៌ចុះ" ។

កាលទន្សាយពោធិសត្វចរចាជាមួយនឹងព្រាហ្មណ៍ បានពោលគាថានេះតទៅទៀតថា:

**ន សសស្ស តិលំ អត្ថិ ន មុគ្គា នបិ តណ្ឌុលា**
**ឥមិនា អគ្គិនា បក្កំ មមំ ភុត្វា វនេ វសាតិ ។**

"ទន្សាយមិនមានល្ងមិនមានសណ្តែកបាយទេ សូម្បីតែអង្ករក៏គ្មានដែរ សូមអញ្ជើញតាពីសាសាច់ខ្ញុំដែលឆ្អិនដោយភ្លើងនេះ ហើយនៅធ្វើសមណធម៌ក្នុងដងព្រៃចុះ" ។

វេលានោះ ព្រះឥន្ទក៏គាក់តែងគំនររងើកភ្លើង ១ សុទ្ធតែរងើក ដោយទេ-វានុភាព ហើយមកប្រាប់ពោធិសត្វវិញ ៗ ទន្សាយបណ្ឌិតក៏ក្រោកចាកទីដំណេកដើរសំដៅទៅឈរជិតរងើកភ្លើង ហើយនិយាយថា "ប្រសិនបើមានពួកសត្វល្អិតនៅជែកត្រង់ចន្លោះរោមរបស់យើង សូមកុំឲ្យស្លាប់ឡើយ" ទើបរលាស់ខ្លួន ៣ ដងស្រេចហើយ ក៏ដាក់សរីរៈទាំងស្រុងឲ្យជាប្រមុខនៃទាន គឺលោតទំលាក់ខ្លួនចុះទៅលើគំនររងើកភ្លើងដែលកំពុងឆេះព្រាលឆ្អៅ ដោយចិត្តរីករាយឥតរួញរា ដូចសត្វហង្សចុះមកទំលើគំនរផ្កាឈូកក្រហម គួរឲ្យស្ញើចណាស់ សូម្បីតែរណ្ដៅរោមសរីរៈរបស់ពោធិសត្វក៏ឥតក្ដៅឬឆេះដោយភ្លើងឡើយ គឺបែរជាត្រជាក់ដូចជាគេចូលទៅក្នុងគំនរទឹកសន្សើមវិញ ៗ លំដាប់នោះ ទន្សាយបណ្ឌិតហៅឥន្ទព្រាហ្មណ៍មកសួរថា "តាព្រាហ្មណ៍អើយ! តាធ្វើភ្លើងឲ្យត្រជាក់អ្វីម្ល៉េះ? សូម្បីតែរណ្ដៅរោមរបស់ខ្ញុំ ក៏ឥតក្ដៅឡើយ ម្ដេចបានជាយ៉ាងនេះ? ៗ ឯឥន្ទព្រាហ្មណ៍ឆ្លើយតបថា "ទេ! លោកបណ្ឌិតអើយ! ខ្ញុំឯងមិនមែនព្រាហ្មណ៍ទេ គឺជាព្រះឥន្ទពិត ខ្ញុំមកនេះដោយចង់ល្បងមើលទេតើ" ៗ ពោធិសត្វក៏បន្លឺសីហនាទតបថា "បពិត្រទេវរាជ! កុំថាឡើយព្រះអង្គម្នាក់ឯង បើទុកជាលោកសន្និវាសទាំងមូលមកចង់ល្បងមើលទានរបស់ខ្ញុំក៏ដោយ ត្រង់របស់អ្វីដែលខ្ញុំមិននឹកចង់ឲ្យនោះគ្មានទេ" ៗ លំដាប់នោះ សក្កទេវរាជពោលថា "ម្នាលសសបណ្ឌិត! គុណរបស់

អ្នកចូរតាំងនៅប្រាកដអស់ ១ កប្បចុះ" ហើយក៏ច្របាច់ពូតថ្មភ្នំបញ្ចេញជ័រ យកទៅគូរកេសជាសសលក្ខណៈ (គំនូរសត្វទន្សាយ) ភ្ជាប់ទីងមណ្ឌលព្រះចន្ទ្រ រួចហើយនាំពោធិសត្វទៅឲ្យដេកនៅក្នុងកន្ទ្រងដដែល ហើយហោះត្រឡប់ទៅកាន់ទេវលោកវិញ ។

ឯសត្វបណ្ឌិតទាំង ៤ រូបបានព្រមព្រៀងគ្នា មានចិត្តស្មោះសរទើងគ្នា បានញុំាងសីលរបស់ខ្លួនឲ្យពេញបរិបូណ៌ ព្រមទាំងរក្សា៖ឧបោសថ លុះអស់ជីវិតទៅក៏បានទៅកើតក្នុងស្ថានសួគ៌ទាំងអស់ ។

ព្រះសាស្ដាទ្រង់ប្រជុំជាតកថា : សត្វភេក្នុងកាលនោះ បេរវិលមកជាអានន្ទ. សត្វចចកបានជាមោគ្គល្លាន, សត្វស្វាបានជាសារីបុត្ត. ព្រះឥន្ទបានជាអនុរុទ្ធ, ឯទន្សាយបណ្ឌិតបានជាតថាគតហ្នឹងឯង ។

## អវសានគាថា

ទន្សាយបណ្ឌិតជាតកនេះ ខ្ញុំបានត្រិះរិះប្រែបាលី
ហើយរៀបរៀងមកជាសេចក្ដី ខេមរៈយ៉ាងខ្ញុំល្មមស្ដាប់បាន ។
គោលរឿងចតុក្កនិបាត វណ្ណនាជាអាទិ៍ជាដើមដាន
ខ្ញុំថ្លែងរឿងនេះតាមលំអាន អ្នកប្រាជ្ញបុរាណពីជាន់ចាស់ ។
សូមជាតិកម្ពុជាសម័យថ្មី កបដោយសិរីឆាប់ហើស
សុខសាន្តសប្បាយទាំងក្មេងចាស់ ពាក្យថាភាគខ្វះកុំបីត្រូ ។

សូមឲ្យសាសនាព្រះជិនស្រី រុងរឿងល្បាញល្បីខ្ចរខ្ចី
ដូចសូរិយោទ័យផ្សាយពន្លឺ ញ៉ាំងលោកឲ្យភ្លឺដោយរស្មី ។
សូមព្រះប្រិយមហាក្សត្រិយ៍ សោយសុខសម្បត្តិលើផែនដី
សូមមានតេជះតបៈល្បី ឈ្នះជនអប្រិយសព្វទិសទស ។
សូមឲ្យពុទ្ធសាសនៈ- បណ្ឌិតប្រក័ក្យល្បីកើតឈ្មោះ
ផ្សព្វផ្សាយរង្សីល្អឥតមោះ ភ្លឺឆ្ងាយសាយសុសសព្វភាគ ។
ដូចកល់ឧភាសព្រះអាទិត្យ កំចាត់ងងឹតក្នុងមេឃា
ឬដូចស្មើដួងចន្ទ្រា ចេញផុតនភាស្រឡះអើយ ។

ចប់រឿងសព្វចាំស័ល

ជនពាលឧបមាជាអ្វី?

ជនពាលាប្រាជ្ញនិន្ទាថាព្រៃស្តុក
ព្រោះផ្តល់ទុក្ខឲ្យអ្នកស្រុកធុកវេទនា,
ថាកើតមកឲ្យតែធ្ងន់ពសុធា
ព្រោះតែវាគ្រារស់នៅផៅលាមក ។

យូរ·អ៊ុន

## ពិធីផ្ទេរពុទ្ធសាសនបណ្ឌិត្យ
## ជូនមហារាជរដ្ឋាភិបាលខ្មែរ

(តមក)

បានជានាំឲ្យគីតយន្តផ្ទះនោះកាន់តែទុព្វលភាព ក៏ក្រអន់ទន់ខ្សោយជាលំដាប់ ដូចគ្នានឹងហេតុដែលធ្វើឲ្យស្ទនស្ទក់ដំណើរខាងកិច្ចការបណ្ណាគារ មានការបោះពុម្ពព្រះវិន័យបិដក ព្រមទាំងរូបគំនូររឿងព្រេងជាដើម ។ បើទុកជាមានឧបសគ្គទាំងនេះក៏គង់តែទស្សនាវដ្តី កម្ពុជសុរិយា "ព្រះអាទិត្យកម្ពុជរដ្ឋ" នៃក្រុមពុទ្ធសាសនបណ្ឌិត្យ នេះតែនៅមានចេញផ្សាយតាមផ្លូវគមនាគមន៍ ចំពោះទៅកាន់ទីប្រជុំនៃពុទ្ធសាសនាទាំងអស់គង់សកលលោក ។ ចំណែកខាងសារទ្រព្យ (Collection) ឯទៀតជាច្រើននៃសារមន្ទីរតូចនេះ មានសភាពសាមញ្ញ តែគួរឲ្យអាណោចអាធ័មពន់ពេកដោយឃើញថាសារទ្រព្យទាំងនោះ បានមកពីអំណោយខេត្តក្រៅ ឬអំពីទិន្នក័ណ្ណាដោយសទ្ធាផ្សេងៗ ។ គេបានទស្សនានូវអំណោយទាំងនេះ ឃើញបរិយោកាសស្ងប់ស្ងាត់នៃវត្ថុអាកបខ្មែរចេញផ្សាយលាយចំរុះទៅនឹងន័យដ៏សុខុម របស់រូបក្បាច់ចំឡាក់ដែលសារ-មន្ទីរគីមេត៍បានធ្វើអំណោយ ។ វត្ថុទាំងនេះជាព័ស្តុតាងធ្វើឲ្យឃើញនូវសហការភាព នៃស្ថាប័នឯកទេសខាងបច្ចិមប្រទេស ទៅនឹងស្ថាប័នឯកទេសខាងបូព៌ាប្រទេស តែមានន័យផ្សេងពីខាងលើនេះទៅទៀត គឺព័ស្តុតាងចំពោះការលាយមូលចូលគ្នាជាឯកច្ឆន្ទនៅរីកលទ្ធឡើងកង់ខាង

លើ វេនចិន្តាខាងពុទ្ធសាសនា និងសិល្បៈខាងសមុទ្រមេឌីទែរ៉ាណេ តាំងពី ២.០០០ ឆ្នាំមុនមក ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលខ្ញុំបានពណ៌នាអំពីវឌ្ឍនធម៌ជាស្រុកជុំឥឡូវនេះ បានចំរើនវ័យឡើងរហូតដល់នីតិភាពតាមច្បាប់ ។ នីតិភាពពិតប្រាកដ ដូចជាយើងធ្លាប់បានឃើញមកជាញឹកញយ នោះបានចំរើនធំឡើងតាំងពីខែមុនៗ ជាច្រើនខែមកហើយ ។ នីតិភាពនេះដែលបានទទួលស្គាល់មកហើយ នឹងត្រូវទទួលអនុម័ត ក្នុងរយៈវេលាមិនយូរប៉ុន្មានតទៅទៀត តាមលំនាំជាស្ថាពរ ។

ចំពោះនីតិភាពនេះ យើងបានឃើញព័ស្តុតាងដ៏ឧឡារិក ក្នុងការទទួលនូវបេតិស័ព្ទផ្សាយចេញពីសភាក្នុងក្រេស៍ នៃពុទ្ធសាសនានៅសីឡូន៍ ។ ព្រឹត្តិការណ៍មានសភាពជាសម្បើមអស្ចារ្យនេះ បានលើកតំកើងនូវកិត្យានុភាពនៃប្រទេសកម្ពុជា ចូលទៅក្នុងផែនការណ៍ខាងផ្លូវប្រាជ្ញា មានសារៈប្រយោជន៍ដ៏សំខាន់វេនប្រជាជាតិ ។ ក្នុងមួយរំពេចនោះ ព្រះសង្ឃដែលកប់បញ្ចូលជាសមាសភាពក្នុងគណៈប្រតិភូខ្មែរបានទទួលបសំសនីយភាពពីក្រុមពុទ្ធសាសនា និងក្រុមពួកបណ្ឌិតទាំងប៉ុន្មាន ដោយក្រុមទាំងនេះបានយល់ជាក់ច្បាស់នូវចំណេះវិជ្ជារបស់លោក ដូចជាចំណេះដ៏ស្ទុះខ្ពស់អម្ពរភាពខាងភាសាពិសិដ្ឋជាដើម ។

ព្រះសង្ឃនិងលោកអ្នកដែលមានភ័ព្វសំណាងបាននិមន្តនិងអញ្ជើញទៅកាន់មហាសន្និបាតនៃសភាក្នុងក្រេស៍នៅសីឡូន៍ គង់បានប្រាប់ច្បាស់

ថា: ពុទ្ធសាសនបណ្ឌិត្យជាទីប្រជុំនៃចិន្តាការសាសនាសកលលោក ហើយយើងមានអំណរដោយបានចាត់ផ្ញើជាទុឡារិកឲ្យនូវក្រមនេះ ទៅរាជរដ្ឋាភិបាលខ្មែរ ដោយយល់ថា អំណើះតទៅពុទ្ធសាសនបណ្ឌិត្យនឹងដំណើរការទៅតាមលំអានដោយព្យាយាមតំកើងប្រទេសកម្ពុជានៅក្នុងឋានៈជាឧត្តមរដ្ឋនៃពុទ្ធសាសនាក្នុងសកលលោក មិនមែនចំពោះត្រឹមតែជំនឿជាយ៉ាងជ្រាលជ្រៅប៉ុណ្ណោះទេ ថែមទាំងបដិភាណនិងតក្កវិទ្យានៃព្រះសង្ឃដែលជាឯកទេសបុគ្គល លោកបានអប់រំសង្ឃបរិយាទៅតាមវិន័យនៃវិជ្ជាស្ថាននេះទៀត ។

ក្នុងអវសានបទនេះ, ខ្ញុំសូមអភ័យទោស ដោយខ្ញុំជាសមាជិកនៃសាលាបាពំងនៅចុងបូព៌ាប្រទេស, ខ្ញុំសូមជូនធនុះជាការគោរពរបស់សាលានេះ ហើយសូមឲ្យកិច្ចការទាំងប៉ុន្មាននៃពុទ្ធសាសនបណ្ឌិត្យ ឲ្យបានសម្រេចនូវជោគជ័យតទៅអនាគត ។ ដើម្បីនឹងឧបត្ថម្ភនូវអង្គការដែលទើបនឹងកើតឡើងជាថ្មី. សាលានេះបានចាត់ពួកតិកនិកឲ្យមកកាន់តំណែងជាអគ្គលេខាធិការដូចលោកស្រីសុយសានការប៉ុលែះ លោកពីអែរឌុយប៉ុង, លោកហ្វ្រង់ស្វាស៍ម៉ារទីនី, ហើយលោក-អ្នកស្រីទាំងនេះក៏បានយកចិត្តទុកដាក់ប្រើវិធីការដែលខ្លួនបានអប់រំ មកប្រើក្នុងវិជ្ជាស្ថាននេះ ។ ខ្ញុំអាចបញ្ជាក់ថា: សាលាបាពំងក្នុងបូព៌ាប្រទេសបានបម្រុងនឹងជួយទ្រទ្រង់នូវវិជ្ជាស្ថាននេះ ទៅតាមបំណងចំពោះផែនការណ៍ដែលជា

សាធារណៈប្រយោជន៍ ក្នុងបញ្ហាគ្រប់យ៉ាងដែលនៅក្នុងកំឡុងគេគន់ក្ដៅ នៃសាលានេះដែលមានសភាពជាវិទ្យាសាស្ត្រ ជាព័ស្តុតាងធ្វើឲ្យឃើញ នូវមេត្រីភាព ដែលអ្នកប្រាជ្ញខាងស្រាវជ្រាវនូវវប្បធម៌ផ្សេងៗ នឹងពួកបណ្ឌិត បានធ្វើសេចក្ដីសាមគ្គីរួបរួមគ្នាជាឯកភាពទៅកាន់ឧត្តមគតិតែមួយ ជាសាធារណៈព្រមទាំងសេចក្ដីទុកចិត្តគ្នាទៅវិញទៅមក ។

## សុន្ទរកថា ព្រះតេជព្រះគុណ ហែល-មាស

## រដ្ឋមន្ត្រីក្រសួងធម្មការនិងសិល្បករ

ព្រះករុណាជាម្ចាស់ជីវិតលើត្បូង,

លោកស្ងួនសាធារណរដ្ឋ,

សម្ដេច (ខាងព្រះសង្ឃ),

ទ្រង់,

ព្រះថេរានុត្ថេរៈ,

ព្រះតេជព្រះគុណ,

លោកស្រី,

លោកអ្នកទាំងឡាយ !

បើតាមពិនិត្យនូវលក្ខណៈដែលមានសភាពសាម័ញ្ញទៅ គួរតែឲ្យរំជួលចិត្តពន់ពេក, ព្រោះពិធីដែលទើបនឹងធ្វើមកអម្បាញ់មិញនេះ ក្នុង

អាក់សដ៏មានឫទ្ធានុភាពក្រៃពេក, ទាំងមានន័យប្រកបដោយសារៈសំខាន់ដែលជាប្រស្នាខាងសីលធម៌សុខុមគម្ភីរភាព ។

ពិធីផ្ទេរក្រសួងនេះ ត្រូវមានមកក្នុងពេលខាងក្រោយនៃការចាត់ចែងទៅតាមធម្មជាតិ ក្នុងកិច្ចដែលរដ្ឋាភិបាលប្រទេសបារាំងបានធ្វើទៅតាមអនុវត្តន៍នៃកិច្ចព្រមព្រៀង ដែលចុះហត្ថលេខាពីថ្ងៃ ១៥ មិថុនា ១៩៥០ ។

ការផ្ទេរជាទ្បាក់នូវអំណាចទាំងនេះ អាចសំគាល់បានថា ព្រះរាជអាណាចក្ររបស់យើងធ្វើដំណើរការទៅកាន់វឌ្ឍនធម៌ រហូតដល់និយ្យានិកភាពជាស្ថាពរ ព្រមទាំងទទួលនូវអធិបតេយ្យខាងក្នុងប្រទេសនៃក្របខ័ណ្ឌក្នុងសហភាពបារាំង ។

ការផ្ទេរក្នុងពេលឥឡូវនេះ មិនមែនផ្ទេរត្រឹមតែក្រុមដែលមានប្រយោជន៍ជាសម្ភារៈនោះទេ គឺផ្ទេរទាំងការព្យាយាមខាងផ្លូវប្រាជ្ញាដែលប្រទេសបារាំងបានដំណើរការមកតាំងពី គ. ស. ១៩៣០ មានឆន្ទៈចង់ឲ្យសហធម្មិក, ព្រះសង្ឃថ្នាក់ជាន់ខ្ពស់ ព្រមទាំងចិន្តាខាងសាសនា នៃកម្ពុជរដ្ឋ រក្សាទុកនូវឋានៈដែលត្រូវបានក្នុងចំណោមប្រជាជាតិទាំងអស់ដែលរួបរួមគ្នានៅក្រោមអធិបតីភាពនៃអចលនសទ្ធាក្នុងពុទ្ធសាសនា ។ វីរិយភាពដែលបំពេញចំពោះវប្បធម៌នៃលទ្ធិពុទ្ធនិយម បានផ្សាយចេញតាំងពី ២០ ឆ្នាំមុនមក ប្រៀបដូចបុប្ផាបទុមអណ្ដែតត្រសែតចេញចាកដើមឡើងពីក្នុងភក់ស្រះដូច្នោះ លុះចម្រើនវ័យវឌ្ឍនាការហើយ

បុប្ផានោះបម្រុងនឹងរីកស្វាងរុងរឿងឡើង ។ ប្រទេសបារាំងបានជួយអភិបាលរក្សា ថែទាំឲ្យបានលូតលាស់តទៅទៀត ការពារព្រមទាំងចិញ្ចឹមបីបាច់ឲ្យចំរើនធាត់ធំ ដោយមានបំណងចង់ឲ្យព្រះពុទ្ធអាណាចក្ររបស់យើងបានស្ថិតនៅក្នុងឋានៈដែលធ្លាប់មានមក ចំពោះប្រពៃណីពិសិដ្ឋខាងសាសនា, ការសិក្សាខាងលទ្ធិសាសនា, ការស្វះស្វែងខាងទំនៀមទម្លាប់ពីបុរាណព្រមទាំងកិច្ចវិវត្តន៍ដោយពិស្តារ ។

សេចក្តីព្យាយាមនោះ ដំបូងឡើយមានឧបសគ្គជាច្រើនប្រការមករាំងរា ព្រោះក្របខ័ណ្ឌខាងសាសនារបស់យើង បានបោះបង់ចោលនូវវប្បធម៌ដើមរបស់ខ្លួន ត្រឡប់និយមចូលទៅក្នុងអនិស្សរភាពក្របខ័ណ្ឌសាសនានៃសមន្តប្រទេសទឹងនានាប្រទេស ។

សេចក្តីព្យាយាមនៃបារាំង បានប្រគល់នូវបទីបមួយចំពោះព្រះសង្ឃរបស់យើង ជាវត្ថុដែលយើងមិនត្រូវបោះបង់ចោល ត្រូវអភិបាលរក្សាតៗមក ព្រមទាំងរចនាស្ទើនោះឲ្យកាន់តែភ្លឺរុងរឿងឡើង ។

ចំពោះកិច្ចការដ៏ប្រសើរនេះ យើងសូមថ្លែងអំណរគុណជាយ៉ាងក្រៃលែងចំពោះប្រទេសបារាំង ។

ដោយហេតុដូចនេះ ប្រទេសកម្ពុជាមិនមែនគ្រាន់តែបានស្ថិតនៅក្នុងឋានៈដែលត្រូវបានចំពោះការព្យាយាមនូវវប្បធម៌ព្រមទាំងសាសនាទេ គឺត្រូវមានសន្ទុះស្មើ ឬ លឿនជាងពួកសមន្តប្រទេសទៅទៀត ។

ជាតក់សនានៃក្រុមពុទ្ធសាសនបណ្ឌិត្យដែលគេបានប្រគល់មកឲ្យយើងក្នុងពេលនេះ, យើងត្រូវព្យាយាមរក្សាទុកនូវកេរ្តិ៍ដំណែលនេះឲ្យគង់វង្សនៅតទៅអនាគត ព្រមទាំងពង្រីកបាន:ដែលបានទទួលនោះឲ្យកាន់តែរីកធំទូលាយឡើង ។

សេចក្ដីព្យាយាមនេះមិនអាចនឹងបន្ថយបានឡើយ ហើយក្រុមព្រះសង្ឃរបស់យើង មុខជានឹងរិះរកវិធីការឲ្យវិរិយភាពនេះដើរទៅកាន់សេចក្ដីចំរើនបាន ។ សេចក្ដីព្យាយាមត្រូវតែបំពេញឲ្យកាន់តែមាំមួនតទៅទៀត តែវិជ្ជាស្ថានដែលរចនាដ៏វិចិត្រនេះស្ថិតនៅក្នុងយុវភាពនៅឡើយ ។ មានគេពោលថា វិជ្ជាស្ថាននេះបានចំរើនវ័យវឌ្ឍនាការដល់ទីតិភាពហើយ ។ តែមានទីតិភាពខ្លះដូចជាផ្នែកខាងផ្លូវចិត្តនឹងការស្រាវជ្រាវរឿងរ៉ាវផ្សេង ៗ ត្រូវតែមានការឧបត្ថម្ភពីអ្នកដទៃ ។ ការឧបត្ថម្ភនេះ យើងបានទទួលដោយសេចក្ដីស្មោះស្ម័គ្រហើយ ។ យើងសូមថ្លែងកតញ្ញូកតវេទីចំពោះអ្នកជួយឧបត្ថម្ភយើង ព្រមទាំងបានណែនាំយើងអំពីទីតិភាពដែលនៅទន់ខ្ចីនៅឡើយទៅកាន់ព្រឹទ្ធភាព (maturité) ដែលមានលក្ខណៈរឹងប៉ឹងចំពោះខ្លួនលែងព្រួយក្នុងការធ្វើដំណើរតទៅអនាគត ។

ចំពោះវត្ថុធាតុទាំងអស់ យើងត្រូវប្រុងប្រយ័ត្នការពារកុំឲ្យកិច្ចការទាំងនោះទុព្វលភាព អន់ទន់ទ្រាយទៅវិញ ។ បក្សាដែលពិសោធន៍នូវស្លាបខ្សោយតែងធ្លាក់ចាកចេញពីសំបុកមិនខាន ។ យើងត្រូវការពារ

កុំឲ្យជួបនូវឧបសគ្គបែបនេះ ។ ព្រោះហេតុដូចនេះ ខ្ញុំសូមថ្លែងនូវអំណរជាយ៉ាងក្រៃលែង ចំពោះសាលាបារាំងចុងបូព៌ាប្រទេសដែលបញ្ចេញរស្មីភ្លឺស្វាងរុងរឿងពាសពេញសកលលោក ដោយសាលានេះបានជួយឧបត្ថម្ភជាយ៉ាងមាំមួននូវវិជ្ជាស្ថានរបស់យើងនេះ ។

អ្នកទទួលភារៈដ៏រឹងប៉ឹងបែបនេះ ដែលបានពិសោធន៍យ៉ាងច្បាស់លាស់ពីមុនមកហើយ អាចធានាអះអាងដោយពិតប្រាកដ មិនគ្រាន់តែរៀបចំកិច្ចការនេះឲ្យបានស្រួលល្អទេ ថែមទាំងធ្វើដំណើរការទៅកាន់សេចក្តីចំរើនជានិរន្តរកាល រហូតដល់សុខុមវិជ្ជានៃភាសាសាស្ត្រនឹងប្រពៃណីនិយមអំពីអតីតកាល ។

ខ្ញុំមិនចង់បញ្ចប់សុន្ទរកថាខ្ញុំ ដោយគ្មានថ្លែងកតញ្ញូនឹងកតវេទិចំពោះពួកបណ្ឌិតដែលមាននាមល្បីល្បាញ ហើយជាអ្នកបានព្យាយាមឧបត្ថម្ភវិជ្ជាស្ថាននេះ តាំងពីដើមរៀងរៀបដកបមក ព្រមទាំងបានជួយទំនុកបម្រុងដោយបច្ច័យព្រមទាំងវីរិយភាព ដើម្បីនឹងរចនានូវវិជ្ជាស្ថានរបស់យើងឲ្យបានឡើងទៅកាន់ឋានៈដែលត្រូវបានក្នុងសម័យបច្ចុប្បន្ន ស្មើមុខនឹងវិជ្ជាស្ថាននៃវប្បធម៌ដែលមានទាំងប៉ុន្មាននៅចុងបូព៌ាប្រទេស ។

បណ្ឌិតទាំងនោះ បានជួយទំនុកបម្រុងប្រទេសកម្ពុជាឲ្យរួចចាកពីអនិស្សរភាពនៃបរទេស ហើយធ្វើឲ្យប្រទេសយើងអាចបានឡើងទៅកាន់

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME-ORIENT



បានដែលគួរបាន ។ យើងសូមថ្លែងនូវអំណរជាពន្ទឹក ព្រមទាំងកតញ្ញូនឹងកតវេទីជាមុន ។

តាំងពីថ្ងៃនេះតទៅ ពុទ្ធសាសនបណ្ឌិត្យ ទៅជាវិជ្ជាស្ថានរបស់ប្រជាជាតិខ្មែរមួយ ដែលយើងត្រូវតែរក្សាទុកនូវកេរ្តិ៍ដំណែលទៅតាមប្រពៃណីនៃប្រទេសបារាំងបានខំព្យាយាមផ្តួចផ្តើម ឲ្យកើតឲ្យមានឡើងនៅប្រទេសយើង ហើយយើងមានសេចក្តីសង្ឃឹមថា ប្រទេសបារាំងនឹងជួយឧបត្ថម្ភនូវវិជ្ជាស្ថាននេះតទៅអនាគត ឲ្យបានស្ថិតនៅក្នុងក្របខ័ណ្ឌសហភាពមួយ ដើម្បីណែនាំឲ្យព្រះរាជអាណាចក្ររបស់យើងបញ្ចេញនូវរស្មីឲ្យកាន់តែភ្លឺស្វាងរុងរឿងតទៅ ។

– ចប់ –

ខ្ញុំគេបែបណាថោកបំផុត?

ខ្មែរតែម្នាក់ធ្លាក់ខ្ញុំគេ, ជាតិសោភ័ន;
បើខ្មែរអន់ខ្ញុំទាំងជាតិថោកបំផុត
ខ្មែរជាន់ប្លៃគង់បង្វែដោះតាមផុត
ឲ្យស្រកស្រុតកិត្តនាមជាមួយផង ។

យូរ - អ៊ុន